# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្ដីប្រចាំខែមីនា



លេខ ២៦៩ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២៣

Issue 269 Volume 23 Before Christ 2566 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរាជទូតអារ៉ាប៊ីសាអ៊ូឌីត ចូលជួបជូនសារតាំង ...... ១
- សម្តេចប្រមុខរដ្ឋស្តីទីជួបសំណេះសំណាលជាមួយគណៈប្រតិភូស្ត្រី ក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា........ ៣
- សម្តេចប្រមុខរដ្ឋស្តីទីអញ្ជើញបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តមុនីជីខលើ ........ ៦
- ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពិនិត្យសម្រេចលើរបៀបវារៈចំនួន៣........ ១០
- ព្រឹទ្ធសភាបើកសម័យប្រជុំលើកទី១០ នីតិកាលទី៤........ ១១
- ព្រឹទ្ធសភារៀបចំវេទិកាថ្នាក់ខណ្ឌជាមួយក្រុមប្រឹក្សា សង្កាត់ ចំនួន៩ខណ្ឌ ក្នុងរាជធានីភ្នំពេញ ........ ១៣
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........ ១៦


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី៥ព្រឹទ្ធសភាទទួលជួបពិភាក្សាការងារ ជាមួយនឹងរដ្ឋមន្ត្រីក្រសួងព័ត៌មាន........ ១៧
- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ អញ្ជើញសម្ពោធបណ្ណាល័យ១ខ្នងនៅសាលាបឋមសិក្សាបឹងក្អែក........ ១៩
- ព្រឹទ្ធសភារៀបចំពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា........ ២១
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញជួបសំណេះសំណាលអាជ្ញាធរឃុំចំនួន៤ ក្នុងស្រុកគំបែរ........ ២៣
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលជាមួយអាជ្ញាធរស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបង........ ២៥
- ក្រុមសមាជិកាព្រឹទ្ធសភាប្រជុំជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានលើគម្រោង PMI-WILL........ ២៧
- លោកគ្រូ អ្នកគ្រូ និងយុវជនកាយរឹទ្ធិវិទ្យាល័យបាត្តំ ទស្សនកិច្ចឈ្វេងយល់អំពីព្រឹទ្ធសភា........ ២៩
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........ ៣១
- ការងារទទួលពាក្យបណ្តឹង........ ៣២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨........ ៣៣
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ៤៥
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៤៦


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ឆ្នាំ២០២៣........ ៥០
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........ ៥១



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លឹម ប៊ុនហុក

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខជី

លោក ទេព មករា

លោក កុក រ៉េ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោកស្រី សុខ សុជាតា

លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីភាពក្នុងពិធីបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធផលនានា ក្នុងវត្តមុនីជីខលើ ភូមិជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Mohammed Ismaeil A.Dahlwy ឯកអគ្គរាជទូតអារ៉ាប៊ីសាអ៊ូឌីត។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរាជទូតអារ៉ាប៊ីសាអ៊ូឌីត ចូលជួបជូនសារតាំង



*ឯកឧត្តម Mohammed Ismaeil A. Dahlwy ជូនសារតាំង សម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Mohammed Ismaeil A. Dahlwy ឯកអគ្គរាជទូតតែងតាំងថ្មី នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអ៊ូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបជូនសារតាំង នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះ ឯកឧត្តម Mohammed Ismaeil A. Dahlwy ត្រូវបានព្រះមហាក្សត្រ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអ៊ូឌីត តែងតាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអ៊ូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសនោះ ឯកឧត្តម Mohammed Ismaeil A. Dahlwy បានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ។ ឯកឧត្តមមានជំនឿជឿជាក់ថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំរួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើគ្រប់វិស័យ ឱ្យកាន់តែខ្លាំងក្លាថែមទៀត ជាពិសេស ឯកឧត្តមនឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យមានស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រអារ៉ាប៊ីសាអ៊ូឌីត នៅព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០២៣នេះ។

ព្រមជាមួយគ្នានោះ សម្តេចប្រមុខរដ្ឋស្តីទីបានកត់សម្គាល់





*ទិដ្ឋភាពប្រគល់ និងទទួលវត្ថុអនុស្សាវរីយ៍*



*ទិដ្ឋភាពរួមក្នុងពិធីជួបសម្តែងការគួរសម*

ដោយសេចក្តីរីករាយចំពោះទំនាក់ទំនងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាបន្តបន្ទាប់។ សម្តេចមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្តម Mohammed Ismaeil A. Dahlwy ជាឯកអគ្គរាជទូតព្រះរាជាណាចក្រអារ៉ាប៊ីសាអ៊ូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំពង្រឹង-ពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេស និងប្រជាជនទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

សម្តេចប្រមុខរដ្ឋស្តីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃកម្ពុជា ត្រៀមខ្លួនជានិច្ចធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តមឯកអគ្គរាជទូត ដើម្បីលើកកម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដើម្បីនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

តាមរយៈឯកឧត្តមឯកអគ្គរាជទូត សម្តេចប្រមុខរដ្ឋស្តីទីបានពាំនាំនូវព្រះរាជបណ្តាំសួរសុខទុក្ខសេចក្តីនឹករលឹកអំពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិ នៃព្រះរាជាណាចក្រកម្ពុជា ថ្វាយព្រះមហាក្សត្រ និងជូនចំពោះថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់-ថ្នាក់ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអ៊ូឌីត។

សម្តេចប្រមុខរដ្ឋស្តីទីបានប្រសិទ្ធពរជូនឯកឧត្តមឯក-អគ្គរាជទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្តុង្គឧត្តមនៅព្រះរាជាណាចក្រ-កម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គឹម សិទ្ធី)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Mohammed Ismaeil A. Dahlwy*

# សម្តេចប្រមុខរដ្ឋស្តីទីជួបសំណេះសំណាលជាមួយគណៈប្រតិភូស្ត្រី ក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ទទួលជួបសំណេះសំណាលជាមួយនឹងគណៈប្រតិភូស្ត្រី*

នាព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង៨:៣០ នាទីព្រឹក នៅសាលសិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសំណេះសំណាលជាមួយនឹងគណៈប្រតិភូស្ត្រីមកពីគ្រប់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន២០០នាក់ ដឹកនាំដោយលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្នុងឱកាសអបអរសាទរខួបទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ក្រោមមូលបទ "ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល"។



*លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី ឡើងថ្លែងសេចក្តីរាយការណ៍*

ក្នុងឱកាសនោះ លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ធ្វើសេចក្តីរាយការណ៍ជូនដោយសង្ខេបអំពីសមិទ្ធផលសំខាន់ៗស្តីពី ស្ថានភាពរបស់ស្ត្រីកម្ពុជា ដែលសម្រេចបានកន្លងមក ដោយមានការសម្របសម្រួលដោយក្រសួងកិច្ចការនារី និងការចូលរួមពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ដែលធ្វើឱ្យកម្ពុជាទទួលបាននូវវឌ្ឍនភាពគួរជាទីមោទនៈនាពេលបច្ចុប្បន្ន។

ក្នុងព្រះបរមនាមព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី បានថ្លែងនូវការកោតសរសើរ និងគាំទ្រមូលបទដែលក្រសួងកិច្ចការនារី បានកំណត់យកឆ្នាំនេះ ពិតជាមានសារសំខាន់ដែលឆ្លុះបញ្ចាំងពីតម្លៃ និងវត្តមានរបស់ស្ត្រីកម្ពុជានាពេលបច្ចុប្បន្ន ក្នុងការចូលរួមថែរក្សាសុខសន្តិភាព និងការពន្លឿនកិច្ចអភិវឌ្ឍលើគ្រប់វិស័យ និងបានឆ្លុះបញ្ចាំងពីចក្ខុវិស័យទៅអនាគតក្នុងការអភិវឌ្ឍ



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញ មានប្រសាសន៍សំណេះសំណាល*

ប្រកបដោយចីរភាព ក្នុងយុគសម័យឌីជីថល ខណៈដែល យើងទាំងអស់គ្នាបានឆ្លងកាត់វិបត្តិកូវីដ-១៩ និងខិតខំប្រឹងប្រែងឆ្ពោះទៅការស្តារសង្គម សេដ្ឋកិច្ច និងការកសាងភាពធន់ និងភាពរឹងមាំរបស់កម្ពុជា ក្រោមម្លប់ នៃសន្តិភាព។

សម្តេចប្រមុខរដ្ឋស្តីទីបានវាយតម្លៃខ្ពស់ចំពោះលទ្ធផល ការងារដែលក្រសួងកិច្ចការនារីសម្រេចបាន ក្នុងកិច្ចការពារ សិទ្ធិស្ត្រី និងជំរុញសមភាពយេនឌ័រនៅគ្រប់កម្រិត និងគ្រប់ វិស័យ ដែលឆ្លើយតបជាវិជ្ជមានទៅនឹងយុទ្ធសាស្ត្រចតុកោណ គ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាល “ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា” ក្នុងការកសាង មូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល កម្ពុជាឆ្នាំ២០៥០។ ក្នុងន័យនេះ ការជំរុញឱ្យមានសមធម៌ យេនឌ័រ និងដំណើរឆ្ពោះទៅរកសមភាពយេនឌ័រពិតប្រាកដ ដែលបានចាត់ទុក “ស្ត្រីគឺជាឆ្អឹងខ្នង នៃសេដ្ឋកិច្ចជាតិ” បាន រួមចំណែកធ្វើឱ្យសម្រេចនូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយកិច្ចការនេះនឹងត្រូវសហការគ្នាឱ្យបានល្អរវាងស្ថាប័ន នីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីឆ្ពោះទៅសម្រេចឱ្យបាន នូវការរំពឹងទុកខ្ពស់ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជា ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៥០។

ក្រោមម្លប់នៃសន្តិភាព និងការអភិវឌ្ឍ ស្ត្រីកម្ពុជាបាន ក្លាយជាកម្លាំងចលករ ដែលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ការអភិវឌ្ឍសង្គម ហើយបច្ចុប្បន្នស្ត្រីមានកាលានុវត្តភាពក្នុងការអនុវត្តសិទ្ធិ ការអភិវឌ្ឍចំណេះដឹង ជំនាញ និងបច្ចេកវិទ្យាឌីជីថលដែលជាមូលដ្ឋានគ្រឹះក្នុងការប្រកួតប្រជែងប្រកបដោយសក្តានុពលនៅក្នុងទីផ្សារសេដ្ឋកិច្ចសេរី ទាំងនៅថ្នាក់ជាតិ អន្តរជាតិ និងនៅក្នុងតំបន់ ហើយស្ត្រីក៏ ជាអ្នកទទួលបានភាគផលពីកិច្ចអភិវឌ្ឍលើគ្រប់វិស័យដែល ធ្វើឱ្យជីវភាពរស់នៅរបស់ស្ត្រី និងក្រុមគ្រួសារមានភាព ប្រសើរឡើង បានកាត់បន្ថយភាពងាយរងគ្រោះ និងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។

សម្តេចប្រមុខរដ្ឋស្តីទី បានសម្តែងនូវការគាំទ្រចំពោះ



*ទិដ្ឋភាពរួមក្នុងពិធីជួបសំណេះសំណាល*




សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រគល់វត្ថុអនុស្សាវរីយដល់គណៈប្រតិភូនារី

រាជរដ្ឋាភិបាល ដែលបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់ដោះស្រាយគម្លាតយេនឌ័រក្នុងវិស័យឌីជីថល និងការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យឌីជីថល ពិតជាមានសារៈសំខាន់ និងចាំបាច់បំផុតក្នុងគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព ស្របតាមគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ដែលបានដាក់បញ្ចូលការលើកកម្ពស់សមភាពយេនឌ័រ រួមមាន៖ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥។ ការដាក់ចេញគោលនយោបាយនេះ បានឆ្លុះបញ្ចាំងពីឆន្ទៈ និងការប្តេជ្ញាខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដោយមិនទុកនរណាម្នាក់ឱ្យនៅឯកោ។

ក្នុងព្រះបរមនាមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី ក្នុងនាមខ្លួនសម្តេចផ្ទាល់ និងក្នុងនាមសមាជិក សមាជិកា ព្រឹទ្ធសភា ដែលជាតំណាងឆន្ទៈប្រជាពលរដ្ឋកម្ពុជា សម្តេចប្រមុខរដ្ឋស្តីទីនឹងបន្តការគាំទ្រចំពោះការតាក់តែងច្បាប់ ការពិនិត្យ ការអនុម័ត និងការតាមដានការអនុវត្តច្បាប់ ដើម្បីធានាឱ្យច្បាប់ទាំងនោះមានការឆ្លើយតបទៅនឹងសមភាពយេនឌ័រ ពោលគឺបម្រើផលប្រយោជន៍ចំពោះប្រជាពលរដ្ឋកម្ពុជាទាំងស្ត្រី និងបុរស។ ឆ្លៀតក្នុងឱកាសនេះ សម្តេចប្រមុខរដ្ឋស្តីទីបានវាយតម្លៃ និងកោតសរសើរក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន ពាក់ព័ន្ធ វិស័យឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងអង្គការជាតិ-អន្តរជាតិ ដែលបានរួមគ្នាប្រារព្ធពិធីនេះឡើងក្រោមមូលបទ "ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" ពិតជាបានឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង លើការថែរក្សាសុខសន្តិភាព ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាជាតិទាំងមូល៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គឹម សិទ្ធី)



សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញថតអនុស្សាវរីយ៍ជាមួយគណៈប្រតិភូនារី តាមក្រសួង ស្ថាប័ន

# សម្តេចប្រមុខរដ្ឋស្តីទីអញ្ជើញបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តមុនីជីខលើ





*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញកាត់ខ្សែបូសម្ពោធសមិទ្ធផលនានា និងកាត់ឫសីមាព្រះវិហារថ្មី*

ព្រះវិហារថ្មី និងសមិទ្ធផលនានាក្នុងវត្តមុនីជីខលើ ស្ថិតក្នុងភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ត្រូវបានប្រារព្ធពិធីបញ្ចុះខណ្ឌសីមា និងសម្ពោធដាក់ឱ្យប្រើ-ប្រាស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុល-សេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រ-កម្ពុជា នាព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ទីប្រឹក្សា ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នៃខេត្តកោះកុង និងពុទ្ធបរិស័ទចំណុះជើងវត្តយ៉ាងច្រើនកុះករ។

ក្នុងឱកាសនោះ លោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង បានជម្រាបជូន អង្គពិធីជ្រាបថា ខេត្តកោះកុងមានវត្តសរុបចំនួន៥៤វត្ត ក្នុងនោះវត្តគណៈមហានិកាយមានចំនួន៤៧វត្ត មានព្រះសង្ឃចំនួន៣៨៨ព្រះអង្គ និងគណៈធម្មកិត្តិកនិកាយមានចំនួន៧វត្ត មានព្រះសង្ឃចំនួន៧០ព្រះអង្គ។ ព្រះវិហារថ្មី និងសមិទ្ធ-ផលនានា ដែលត្រូវបានបញ្ចុះខណ្ឌសីមាសម្ពោធឆ្លងដាក់ឱ្យដំណើរការប្រើប្រាស់ជាផ្លូវការនាពេលនេះ រួមមាន៖ ព្រះវិហារថ្មីទទឹង៨,៥០ម៉ែត្រ បណ្តោយ១១,៥០ម៉ែត្រ កុដិថ្មី ១ខ្នង ទទឹង៦,៥០ម៉ែត្រ បណ្តោយ៧,៥០ម៉ែត្រ ខ្លោងទ្វារ១




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តមុនីជីខលើ*



លោកជំទាវ មិថុនា ភូថង ឡើងរាយការណ៍

និងជងទង់១គូ ព្រមទាំងសមិទ្ធផលផ្សេងៗទៀត។

ក្នុងឱកាសដ៏មហោឡារិកនេះ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវសេចក្តីរីករាយដោយមើលឃើញពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានាក្នុងវត្តមុនីជីខលើនាពេលនេះ ប្រព្រឹត្តទៅយ៉ាងរលូន ឧឡារិក និងអធិកអធមយ៉ាងក្រៃលែង ស្របពេលដែលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងបោះជំហានយ៉ាងរឹងមាំលើមាគ៌ាប្រជាធិបតេយ្យ សន្តិភាព ឯករាជ្យភាព អធិបតេយ្យភាព បូរណភាព ស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមឡើងវិញពីវិបត្តិកូវីដ-១៩ ឱ្យកាន់តែមានភាពធន់ និងបរិយាបន្ន ក្រោមម្លប់សន្តិភាព។

សម្តេចប្រមុខរដ្ឋស្តីទីបានបញ្ជាក់ថា លទ្ធិព្រះពុទ្ធសាសនាបានចាក់ឫសយ៉ាងជ្រៅទៅក្នុងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជា។ ប្រជាពុទ្ធបរិស័ទលោកយកព្រះពុទ្ធសាសនាជាទីពឹង ដើម្បីស្វែងរកសេចក្តីសុខចម្រើនទាំងក្នុងបច្ចុប្បន្នជាតិ និងក្នុងអនាគតជាតិ។ ព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ គឺជាទឹកអម្រិតដែលជនានុជនគ្រប់រូបប្រាថ្នាចង់បានគ្រប់ៗគ្នា។ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់ថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយចារឹកជាបាវចនារបស់ប្រទេសជាតិ "ជាតិ សាសនា ព្រះមហាក្សត្រ" ហើយក្នុងបទចម្រៀងគោរពទង់ជាតិរបស់យើងក៏រំលេចខ្លឹមសារនឹកដល់គុណព្រះពុទ្ធសាសនាផងដែរ។

ស្របពេលជាមួយគ្នានោះ សម្តេចប្រមុខរដ្ឋស្តីទីបានរំលឹកពីអតីតកាលដែលប្រជាជនកម្ពុជាមិនអាចបំភ្លេចបានកាលពីទសវត្សរ៍ឆ្នាំ៧០ ព្រះពុទ្ធសាសនាត្រូវបានអាប់ឱនដោយសារសង្គ្រាម និងត្រូវបានកំទេចបង់ដោយសាររបបប្រល័យពូជសាសន៍ប៉ុលពត។ ព្រះពុទ្ធសាសនាត្រូវបានរស់ឡើងវិញជាមួយនឹងការរស់ឡើងវិញរបស់ប្រទេសជាតិ





ទិដ្ឋភាពអ្នកចូលរួមក្នុងពិធីបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានា




*ទិដ្ឋភាពរួមក្នុងពិធីបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មីនិងសម្ពោធសមិទ្ធផលនានា*

និងប្រជាជនកម្ពុជា កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ តាំងពីពេលនោះមករហូតដល់បច្ចុប្បន្ននេះវិស័យព្រះពុទ្ធ-សាសនាត្រូវបានស្តារ និងអភិវឌ្ឍឡើងវិញយ៉ាងឆាប់រហ័ស ទាំងបរិមាណ និងគុណភាព ហើយកំពុងក្លាយជាកម្លាំងស្នូល នៃសុខដុមនីយកម្មរវាងអ្នកកាន់ព្រះពុទ្ធសាសនា ជាមួយនឹងអ្នកកាន់ជំនឿ និងសាសនាផ្សេងៗទៀតដែលកំពុងមានវត្តមាននៅកម្ពុជាបច្ចុប្បន្ន។

ជាមួយគ្នានោះ សម្តេចប្រមុខរដ្ឋស្តីទីបានថ្លែងនូវការកោតសរសើរចំពោះការដឹកនាំដ៏ត្រឹមត្រូវឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យរាជរដ្ឋាភិបាលបច្ចុប្បន្នសម្រេចបាននូវសមិទ្ធផល នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម យ៉ាងធំសម្បើម គួរជាទីមោទនៈយ៉ាងក្រៃលែង មានជាអាទិ៍៖ **១**.រក្សាការពារបាននូវសន្តិភាព ស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម ស្ថិរភាពនយោ-បាយ និងថែរក្សាការពារបាននូវឯករាជ្យភាព អធិបតេយ្យ-ភាព បូរណភាពដែនដី បានយ៉ាងគត់មត់នៅក្នុងគ្រប់ស្ថាន-ភាព និងគ្រប់កាលៈទេសៈទាំងអស់។ **២**.ដឹកនាំប្រជាជនប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ ដែលត្រូវបានទទួលស្គាល់ថា ជាប្រទេសដែលគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រពៃ ហើយត្រូវបានទទួលស្គាល់ថា ជាប្រទេសឈរនៅលំដាប់លេខ២ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់ពិភពលោក។ **៣**.រក្សាលំនឹងសេដ្ឋកិច្ចក្នុងបរិបទ នៃវិបត្តិជំងឺកូវីដ-១៩យ៉ាងមានប្រសិទ្ធភាព ដោយបានបើកប្រទេសលើគ្រប់វិស័យឡើងវិញ ដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញយ៉ាងឆាប់រហ័សជាមួយនឹងកំណើន៣% ក្នុងឆ្នាំ២០២១ និងកំណើនប្រមាណ៥,២% ក្នុងឆ្នាំ២០២២។ តាមការព្យាករណ៍ឆ្នាំ២០២៣នេះ សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើន៥,៦%។ **៤**.បានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ កាលពីថ្ងៃ៥ ខែមិថុនា ឆ្នាំ២០២២ ប្រកបដោយជោគជ័យ។ **៥**.សម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់ក្នុងឋានៈជាប្រធានអាស៊ាន ដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ព្រមទាំងជាប្រធាន នៃមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) យ៉ាងរលូន និងប្រកបដោយលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់។

ទោះបីស្ថិតក្នុងបរិបទ នៃជំងឺកូវីដ-១៩ ក៏ដោយ ក៏រាជរដ្ឋា-ភិបាលនៅតែបន្តបំពេញបេសកកម្មថែរក្សាសន្តិភាព នៅបណ្តាប្រទេសក្រោមឆ័ត្រអង្គការសហប្រជាជាតិ និងជំរុញការទាក់ទាញការវិនិយោគចូលមកកម្ពុជា ទន្ទឹមនឹងការ

ស្វែងរក និងពង្រីកទីផ្សារថ្មីៗសម្រាប់ការនាំចេញផលិតផលផងដែរ។ ប្រការដែលប្រជាជនកម្ពុជាកំពុងតែរីករាយ និងអបអរផងដែរនោះ គឺអង្គការឃ្លាំមើលការលាងសម្អាតប្រាក់ និងឧក្រិដ្ឋកម្មហិរញ្ញវត្ថុអន្តរជាតិហៅកាត់ថា FATF មានមូលដ្ឋាននៅទីក្រុងប៉ារីស បានដកកម្ពុជាចេញពីបញ្ជីប្រផេះ នៃក្រុមប្រទេសដែលមានហានិភ័យខាងលាងលុយកខ្វក់។

សម្តេចប្រមុខរដ្ឋស្តីទីបានអំពាវនាវដល់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទាំងអស់ សូមអញ្ជើញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៃរដ្ឋសភានីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខនេះ ឱ្យបានគ្រប់ៗគ្នា ដើម្បីជ្រើសរើសអ្នកដឹកនាំប្រទេសជាតិ ដើម្បីការអភិវឌ្ឍ និងការរីកចម្រើនរុងរឿងថ្កើងថ្កានលើគ្រប់វិស័យ។

ជាមួយគ្នានោះ សម្តេចប្រមុខរដ្ឋស្តីទីបានណែនាំដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ សូមបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានល្អនូវការងារមួយចំនួនដូចជា៖ ១-ខិតខំថែរក្សាសុខសន្តិភាព សណ្តាប់ធ្នាប់សង្គមក្នុងគ្រប់មូលដ្ឋានទាំងអស់ ឱ្យបានរឹងមាំជានិច្ច កាត់បន្ថយឱ្យបានជាអតិបរមានូវអំពើអសកម្មទាំងឡាយ ដើម្បីធានាឱ្យប្រជាជនបានរស់ដោយសុខក្សេមក្សាន្តទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ២-ផ្តល់សេវាជូនប្រជាជនដោយគ្មានការរើសអើង ប្រកបដោយតម្លាភាព គុណភាព គណនេយ្យភាព ប្រសិទ្ធភាព និងឆាប់រហ័ស ៣-សហការជាមួយនឹងស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់ ដើម្បីលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅគ្រប់មូលដ្ឋាន ៤-ខិតខំកៀរគរសប្បុរសជនក្នុងតំបន់ និងក្រៅតំបន់ចូលរួមពង្រឹង និងពង្រីកវិស័យព្រះពុទ្ធសាសនាឱ្យមានការរីកចម្រើនជាបន្តបន្ទាប់ ដោយឡែកក៏សូមចូលរួមយកចិត្តទុកដាក់ថែរក្សាការពារព្រះវិហារថ្មី និងសមិទ្ធផលនានា ដែលបានសម្ពោធដាក់ឱ្យប្រើប្រាស់នាពេលនេះ ឱ្យបានគង់វង្សទុកជាសម្បត្តិគរុភណ្ឌរបស់វត្ត សម្រាប់ធ្វើបុណ្យទានតាមប្រពៃណីព្រះពុទ្ធសាសនា ជាយូរអង្វែងតរៀងទៅ ៥-សហការជាមួយនឹងអង្គភាពដែលបោះទីតាំងនៅក្នុងស្រុកស្រែអំបិល រួមគ្នាការពារទ្រព្យសម្បត្តិរដ្ឋ ការពារធនធានធម្មជាតិ ទុកប្រើប្រាស់ឱ្យបានយូរអង្វែង និងទុកជាមរតកសម្រាប់ប្រទេសជាតិ និងសម្រាប់កូនចៅគ្រប់ជំនាន់តរៀងទៅ និង៦-បន្តចាក់វ៉ាក់សាំងតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ព្រមទាំងបន្តអនុវត្តនូវវិធានការ ៣ការពារ និង៣កុំ ឱ្យបានខ្ជាប់ខ្ជួនកុំបីមានការធ្វេសប្រហែសឡើយ៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គឹម សិទ្ធី)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញចែកអំណោយដល់ប្រជាពលរដ្ឋ*



*វត្តមុនីជីខលើ នៅភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង*

# ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពិនិត្យសម្រេចលើរបៀបវារៈចំនួន៣



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍*

នាថ្ងៃពុធ ទី១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០ នាទីព្រឹក ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាបានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ រួមមាន៖

១-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ នីតិកាលទី៤។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការពិសេសសុំដាក់សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៤។

៣-កំណត់របៀបវារៈ កាលបរិច្ឆេទ និងសមាសភាពលេខាធិការសម័យប្រជុំលើកទី១០ព្រឹទ្ធសភានីតិកាលទី៤។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃចន្ទទី៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបើកសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៤ ដោយមានរបៀបវារៈចំនួន២រួមមាន៖

១-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ព្រឹទ្ធសភានីតិកាលទី៤។

២-ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គឹម សិទ្ធី)



*សមាជិកព្រឹទ្ធសភាលើកដៃអនុម័ត ដើម្បីបើកសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤*

# ព្រឹទ្ធសភាបើកសម័យប្រជុំលើកទី១០ នីតិកាលទី៤



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ដឹកនាំការបើកសម័យប្រជុំ លើកទី១០ នីតិកាលទី៤*

នាព្រឹកថ្ងៃចន្ទ ទី៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០ នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាបានបើកសម័យប្រជុំលើកទី១០ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

សមាជិកព្រឹទ្ធសភាមានវត្តមានចំនួន៥៩រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៩និងលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

ក្នុងអំឡុងពេលចន្លោះសម័យប្រជុំព្រឹទ្ធសភាបីខែនេះ ថ្នាក់ដឹកនាំ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការក្រុមភូមិភាគនានា ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិកសមាធិកាព្រឹទ្ធសភា បានខិតខំបំពេញភារកិច្ចរៀងៗខ្លួនដោយសម្រេចបានលទ្ធផលផ្លែផ្កាជាគុណប្រយោជន៍ដល់ជាតិ និងប្រជាពលរដ្ឋ។



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញឡើងអានរបាយការណ៍*

សកម្មភាពលេចធ្លោ គឺការយកចិត្តទុកដាក់ធ្វើសកម្មភាពនៅមូលដ្ឋានតាមរយៈការចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងសមាជិកសមាជិកាព្រឹទ្ធសភា ដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ដោះស្រាយសំណូមពរ និងបញ្ហាប្រឈមនានា ព្រមទាំងការចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។ គណៈកម្មការទាំង១០ និងក្រុមនានា ដែលជាសេនាធិការរបស់ព្រឹទ្ធសភាបានជួបពិភាក្សាការងារជាមួយនឹងក្រសួងស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារតាមវិស័យ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ជាពិសេសជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាតួអង្គសំខាន់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភាសូមគោរពកោតសរសើរ ចំពោះរាជរដ្ឋាភិបាលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានពុះពារឧបសគ្គគ្រប់បែបយ៉ាងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការរក្សាសន្តិភាព ស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមបានរឹងមាំ,ការគ្រប់គ្រងការឆ្លងរាតត្បាត នៃជំងឺកូវីដ-១៩បានល្អ, ការសម្រេចបានកំណើនសេដ្ឋកិច្ចឡើងវិញក្នុងអំឡុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ជាមួយនឹងការជួយប្រជាជនឱ្យរក្សាបានលំនឹងជីវភាព, ភាពជោគជ័យ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥, ការអភិវឌ្ឍគោលនយោបាយបរទេសឯករាជ្យដោយផ្អែកលើច្បាប់ ដែលបានធានានូវផលប្រយោជន៍ជាសារវន្តរបស់កម្ពុជា និងភាពជោគជ័យដ៏ត្រចះត្រចង់ក្នុងការរៀបចំ និងដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន ដែលបានធ្វើឱ្យកិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជាលេចត្រដែតឡើងលើឆាកអន្តរជាតិ។

ព្រឹទ្ធសភាសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ

ចំពោះការគាំទ្រដ៏ថ្លៃថ្លាពីគ្រប់មជ្ឈដ្ឋានដៃគូនានា និងគ្រប់ស្ថាប័នជាតិ ដែលញ៉ាំងឱ្យព្រឹទ្ធសភាដំណើរការទៅមុខដោយរលូន។

**របៀបវារៈទី២៖ ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។**

សមាជិកព្រឹទ្ធសភាហត្ថលេខីចំនួន២១រូប បានស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រង់ប្រការ២ ប្រការ៧ ប្រការ៨ ប្រការ២៩ ប្រការ៣៩ ប្រការ៤២ ប្រការ៥៧ ប្រការ៦០ ប្រការ៧២ និងប្រការ៨៤ ហើយសេចក្តីស្នើនេះធ្វើឡើងក្នុងគោលបំណងសំខាន់ៗដូចតទៅ៖

១-បង្កើតឱ្យមាននីតិវិធីអនុវត្តជាក់លាក់ សម្រាប់ធានានូវការប្រព្រឹត្តទៅដោយរលូនក្នុងដំណើរការសម័យប្រជុំដំបូង នៃនីតិកាលនីមួយៗ របស់ព្រឹទ្ធសភាស្របតាមស្មារតីមាត្រា១០៦ថ្មី (ពីរ) មាត្រា១០៩ថ្មី និងមាត្រ១១៤ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ និងសង្គតិភាពទៅនឹងការអនុវត្តរបស់រដ្ឋសភា។

២-អនុញ្ញាតឱ្យដំណើរការសម័យប្រជុំព្រឹទ្ធសភា អាចធ្វើទៅតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមស្មារតីមាត្រា១០៩ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រការ៦១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងការអនុវត្តជាក់ស្តែងក្នុងបរិបទកូវីដ-១៩។

៣-ធានាឱ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការទំនាក់ទំនងការងាររបស់ព្រឹទ្ធសភាជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ព្រមទាំងបំពេញការងារការទូតសភាឱ្យកាន់តែមានប្រសិទ្ធភាព និងសង្គតិភាពទៅនឹងការអនុវត្តរបស់រដ្ឋសភា ។

ជារួមការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភារៀបចំឡើងដើម្បីកែសម្រួលបំពេញបន្ថែមនូវខ្លឹមសារ ដើម្បីឱ្យមានសង្គតិភាពទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ បរិបទ នៃការវិវឌ្ឍថ្មី និងការអនុវត្តរដ្ឋសភា ព្រមទាំងស្របទៅនឹងស្ថានភាព នៃការអនុវត្តជាក់ស្តែងក្នុងការធានាបាននូវនិរន្តរភាពនិងកិច្ចដំណើរការជាប្រក្រតីរបស់ព្រឹទ្ធសភា។



*ឯកឧត្តម អ៊ុក ប៊ុនឈឿន ឡើងរាយការណ៍អំពី ពិនិត្យសិក្សា លើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា*

តំណាងសមាជិកព្រឹទ្ធសភាហត្ថលេខី អញ្ជើញមកការពារសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសំឡេងគាំទ្រចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ ទេព មករា រូបភាព៖ វ៉ាន់ ពិសិដ្ឋ)




*សមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា*

# ព្រឹទ្ធសភារៀបចំវេទិកាថ្នាក់ខណ្ឌជាមួយក្រុមប្រឹក្សា សង្កាត់ ចំនួន៩ខណ្ឌ ក្នុងរាជធានីភ្នំពេញ




*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ីម កា អញ្ជើញជាអធិបតីភាពក្នុងអង្គវេទិកាថ្នាក់ខណ្ឌ*

ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់បានដកពិសោធន៍ និងផ្លាស់ប្តូរយោបល់ឆ្លុះបញ្ចាំងអំពីការអនុវត្តការងារ និងបញ្ហាសេសសល់មួយចំនួនដែលត្រូវកែលម្អ នាព្រឹកថ្ងៃ២ ខែមីនា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំវេទិកាស្តីពី ការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវាជូនប្រជាជនប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព ក្រោមអធិបតីភាពបើករបស់ឯកឧត្តមកិត្តិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលម៉ូឌែន៥ ស្ថិតក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីអាជ្ញាធរខណ្ឌចំនួន៩រួមមាន៖ ខណ្ឌឫស្សីកែវ ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌជ្រោយចង្វារ ខណ្ឌមានជ័យ ខណ្ឌបឹងកេងកង ខណ្ឌចំការមន និងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងមហាផ្ទៃ រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ សរុបចំនួន៣៦០នាក់។

ក្នុងនាមព្រឹទ្ធសភា ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** បានវាយតម្លៃខ្ពស់ចំពោះក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ និងក្រុមប្រឹក្សាសង្កាត់ទាំង៩ខណ្ឌ ក្នុងរាជធានីភ្នំពេញ ដែលបានខិតខំរៀបចំវេទិកានាពេលនេះ ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់ បានដកពិសោធន៍ និងផ្លាស់ប្តូរយោបល់ ឆ្លុះបញ្ចាំងអំពីការអនុវត្តការងារបានល្អ និងបញ្ហាសេសសល់មួយចំនួនដែលត្រូវកែលម្អ។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតប្រធានស្តីទីព្រឹទ្ធសភា





*ទិដ្ឋភាពអាជ្ញាធរចំនួន៩ខណ្ឌ ចូលរួមក្នុងអង្គវេទិកា*



ទិដ្ឋភាពរួមក្នុងអង្គវេទិកាថ្នាក់ខណ្ឌ

បានកត់សម្គាល់ថា ឆ្នាំ២០២២-២០២៣ ជាឆ្នាំទី១ នៃការអនុវត្តផែនការសកម្មភាពរបស់ក្រុមប្រឹក្សាសង្កាត់ អាណត្តិទី៥ នៅរាជធានីភ្នំពេញ ក្នុងការអភិវឌ្ឍមូលដ្ឋាន ការបម្រើសេវាជូនប្រជាជនបានល្អធានាបាននូវសុខសន្តិភាព ជីវភាព សុខភាព និងសមធម៌ ព្រមជាមួយនឹងការបន្តជំរុញការងើបឡើងវិញ នៃកំណើនសេដ្ឋកិច្ច ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ នឹងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប្រធានស្តីទីព្រឹទ្ធសភា បានគូសបញ្ជាក់ថា វេទិកានាពេលនេះ បានឆ្លុះបញ្ចាំងពីលទ្ធផល នៃការអនុវត្តការងារនាពេលកន្លងមក និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ ស្របទៅតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (គ.ជ.អ.ប)តាមដំណាក់កាលថ្មី នៃការអនុវត្តមូលដ្ឋានសង្កាត់ឆ្នាំ២០២២-២០២៣ ជាពិសេសឆ្លើយតបទៅតាមសំណូមពររបស់ក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌទាំង៩ លើះ

-ការបូកសរុបលទ្ធផលការងារ និងឆ្លុះបញ្ចាំងការអនុវត្តកម្មវិធីគម្រោងផែនការអភិវឌ្ឍគោលនយោបាយថ្នាក់មូលដ្ឋាន(ឆ្នាំ២០២២-២០២៣) អាណត្តិចាស់កន្លងផុត។

-ការអភិវឌ្ឍមូលដ្ឋានក្រុមប្រឹក្សាសង្កាត់ ខណ្ឌ បានលទ្ធផលល្អជាអតិបរមាក្នុងការលើកស្ទួយជីវភាពប្រជាជនកាន់តែប្រសើរឡើង ធានាបានសុខសុវត្ថិភាព។

-ត្រៀមលក្ខណៈសម្បត្តិក្រុមប្រឹក្សាសង្កាត់ ខណ្ឌទាំងអស់ចូលរួមគ្រប់ដំណាក់កាលបោះឆ្នោតឈានទៅសម្រេចបានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ទទួលបានជោគជ័យ។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានបញ្ជាក់ផងដែរ ថាទោះបីជាមានចំណុចខ្វះខាតតិចតួចក៏ដោយ ក៏រួមគ្នាគិត



ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយអ្នកចូលរួមវេទិកា



*ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជា ជេដ្ឋ អញ្ជើញបិទអង្គវេទិកា*


*ឯកឧត្តម ម៉ាន់ ឈឿន ឡើងមានមតិក្នុងអង្គវេទិកា*

និងស្វែងរកដំណោះស្រាយ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍ និងការផ្តល់សេវានៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាពធានាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញឱ្យកាន់តែមានភាពប្រសើរឡើង ស្របតាមការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដំណាក់កាលទី២(២០២១-២០៣០) ឱ្យទទួលបាននូវសមិទ្ធផលថ្មីៗកាន់តែល្អប្រសើរថែមទៀត។

បន្ទាប់ពីបានដំណើរការពេញមួយព្រឹករួចមក នាវេលាម៉ោង១២ថ្ងៃត្រង់ អង្គវេទិកាបានរៀបចំពិធីបិទក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ជេដ្ឋ** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ជេដ្ឋ** បានវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងផុសផុលពីសំណាក់ក្រុមប្រឹក្សាសង្កាត់ និងអាជ្ញាធរពាក់ព័ន្ធទាំង៩ខណ្ឌ ដែលបានលើកឡើងនូវបញ្ហាប្រឈម ព្រមទាំងមានការចូលរួមស្រាយបំភ្លឺពីសំណាក់វាគ្មិនដែលអញ្ជើញមកពីតំណាងក្រសួងនិងអង្គភាពពាក់ព័ន្ធនានាដែលបានញ៉ាំងឱ្យអង្គសិក្ខាសាលាទាំងមូលទទួលបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត បានគូសបញ្ជាក់ថាអង្គវេទិកាពេញមួយព្រឹកនេះ នឹងបង្កើននូវបទពិសោធន៍ និងចំណេះដឹងបន្ថែមទៀត សម្រាប់ក្រុមប្រឹក្សាសង្កាត់ យកទៅធ្វើជាដើមទុន ក្នុងការអនុវត្តការងារជាក់ស្តែង ព្រមទាំងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍ស្របទៅតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (គ.ជ.អ.ប)តាមដំណាក់កាលថ្មី នៃការអនុវត្តមូលដ្ឋានសង្កាត់ឆ្នាំ២០២២-២០២៣ កាន់តែមានប្រសិទ្ធភាពថែមទៀត៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)



*ទិដ្ឋភាពអាជ្ញាធរចំនួន៩ខណ្ឌ ចូលរួមក្នុងពិធីបិទអង្គវេទិកាថ្នាក់ខណ្ឌ*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាថ្ងៃពុធ ទី១ ខែមីនា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋរស់នៅសង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ស្តេចយាងពីទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិនមកកាន់មាតុប្រទេសវិញ។



❈នាថ្ងៃសុក្រ ទី៣ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញពិនិត្យវឌ្ឍនភាព នៃការកសាងអគារសិក្សាថ្មី១ខ្នង នៅសាលាបឋមសិក្សាទេពនិម្មិត ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ព្រមទាំងនាំយកនូវទេយ្យវត្ថុ គ្រឿងឧបភោគបរិភោគមួយចំនួន និងបច្ច័យប្រគេនដល់ព្រះសង្ឃនៅវត្តទេពនិម្មិត និងវត្តពង្ររង្សី ហៅវត្តជ្រៃម្រាក់ ស្ថិតក្នុងឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។



❈នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆេព ខន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារថ្ងៃត្រង់ ដែលរៀបចំឡើងដោយគណៈកម្មការទី៨ព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរខួបទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆេព ខន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យការកសាងព្រះវិហារថ្មី នៅវត្តលុម្ពិនីសាលវ៍ននារាម (ហៅវត្តអូរសោម) ស្ថិតក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់៕



# គណៈកម្មការទី៥ព្រឹទ្ធសភាទទួលជួបពិភាក្សាការងារ ជាមួយនឹងរដ្ឋមន្ត្រីក្រសួងព័ត៌មាន





*គណៈកម្មការទី៥ព្រឹទ្ធសភាទទួលជួបពិភាក្សាការងារជាមួយនឹងក្រសួងព័ត៌មាន*

ដើម្បីបង្កើនទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធថែមទៀត រវាងគណៈកម្មការទី៥ព្រឹទ្ធសភា ជាមួយនឹងក្រសួងព័ត៌មាន នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣នេះ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់ក្រសួងព័ត៌មានក្នុងឆ្នាំ២០២២ និងទិសដៅអនុវត្តសកម្មភាពបន្តឆ្នាំ២០២៣ យន្តការ និងវិធានការ នៃការគ្រប់គ្រងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ អ្នកសារព័ត៌មានតាមបណ្តាញសង្គម ដែលកំពុងមានសកម្មភាពនាពេលបច្ចុប្បន្ន ការវិវឌ្ឍ នៃដំណើរការកសាងសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន និងបញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងវិស័យព័ត៌មាន។

ក្រៅពីសេចក្តីរាយការណ៍អំពី តួនាទី ភារកិច្ចសំខាន់ៗរបស់ក្រសួងព័ត៌មានក្នុងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ការពង្រឹង និងពង្រីកអង្គភាពផ្សាយទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការគ្រប់គ្រងវិស័យព័ត៌មាន ការកសាងឯកសារបទដ្ឋានគតិយុត្ត សកម្មភាពការងារតាមដាន និងចំណាត់ការលើការផ្សព្វផ្សាយព័ត៌មាន និងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសារព័ត៌មាន និងសោតទស្សន៍ ឯកឧត្តម **ខៀវ កាញារីទ្ធ** បានបញ្ជាក់ថា ក្រោមការដឹកនាំប្រកប



*ទិដ្ឋភាពក្នុងពិធីជួបពិភាក្សាការងារ*

ដោយភាពប៉ិនប្រសប់ និងឈ្លាសវៃរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កម្ពុជាបាននឹងកំពុងរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្ដាប់ធ្នាប់សង្គម និងជំរុញការអភិវឌ្ឍលើគ្រប់វិស័យ បើទោះបីមានផលវិបាក និងបញ្ហាប្រឈមមួយចំនួនដែលបានបង្កឡើងដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ។ ក្នុងនោះវិស័យព័ត៌មាន និងសោតទស្សន៍ កាន់តែមានការរីកចម្រើនបន្ថែមទៀត ស្របតាមការវិវឌ្ឍរីកចម្រើន នៃបច្ចេកវិទ្យាព័ត៌មាននាពេលបច្ចុប្បន្ន។ ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយភាពចម្រុះ និងគ្រប់ទស្សនៈ បាននឹងកំពុងបំពេញតួនាទី ភារកិច្ចយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន ព្រឹត្តិការណ៍ ឬហេតុការណ៍ផ្សេងៗដែលបានកើតឡើងទាំងក្នុងប្រទេស និងពិភពលោក ជូនដល់សាធារណជនបានយ៉ាងទូលំទូលាយ និងទាន់សភាពការណ៍។

ឯកឧត្តម **ខៀវ កាញារីទ្ធ** បានបន្ថែមទៀតថា ភាពសម្បូរបែប នៃមធ្យោបាយរបស់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា នាពេលបច្ចុប្បន្ន បានអនុញ្ញាតឱ្យសាធារណជនអាចទទួលបានព័ត៌មានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ការរីកចម្រើន នៃវិស័យព័ត៌មាន និងសោតទស្សន៍នេះ បានបញ្ជាក់យ៉ាងច្បាស់នូវការប្ដេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន ក្នុងការធានានូវការគោរពសិទ្ធិសេរីភាពសារព័ត៌មាន សិទ្ធិសេរីភាពខាងការបោះពុម្ពផ្សាយ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន ដែលមានចែងក្នុងច្បាប់របបសារព័ត៌មាន និងច្បាប់ដទៃទៀត ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានសាទរចំពោះការរីកចម្រើនឥតឈប់ឈររបស់វិស័យព័ត៌មាន ការអនុវត្តតួនាទី ភារកិច្ច ក៏ដូចជាការដាក់ចេញនូវវិធានការនានារបស់ក្រសួងព័ត៌មាន ដែលធ្វើឱ្យក្រសួងគ្រប់គ្រងបាន និងមានចំណាត់ការបានទាន់ពេលវេលា ព្រមទាំងទទួលបាននូវលទ្ធផលដ៏ល្អប្រសើរ ។

ក្នុងនាមគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** បានស្នើឱ្យក្រសួងព័ត៌មាន ក៏ដូចជាយន្តការនានា ចូលរួមស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា ពាក់ព័ន្ធនឹងការអនុវត្តតួនាទី ភារកិច្ចក្នុងវិស័យព័ត៌មាននៅថ្នាក់ក្រោមជាតិ។ ពីព្រោះថា កាលពីពេលកន្លងទៅនេះ គណៈកម្មការទី៥ព្រឹទ្ធសភាបានចុះបំពេញបេសកកម្មនៅតាមបណ្ដាខេត្តនានា ឃើញថាមានចំណុចខ្វះខាត សេសសល់មួយចំនួននៅមិនទាន់អនុវត្តបានល្អគ្រប់ជ្រុងជ្រោយ ដែលអាជ្ញាធរមូលដ្ឋានលើកឡើង៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)



*លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ទី បូរ៉ាស៊ី ជូនវត្ថុអនុស្សាវរីយ៍ដល់ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន*



*សមាជិក សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយនឹងគណៈប្រតិភូក្រសួងព័ត៌មាន*

# ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ អញ្ជើញសម្ពោធបណ្ណាល័យ១ខ្នង នៅសាលាបឋមសិក្សាបឹងក្អែក



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ អញ្ជើញជាអធិបតីភាពក្នុងពិធីសម្ពោធបណ្ណាល័យ*

បណ្ណាល័យចំនួន១ខ្នង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធក្នុងសាលាបឋមសិក្សាបឹងក្អែក ស្ថិតនៅភូមិបឹងក្អែក ឃុំពាមមានជ័យ ស្រុកពាមរក៍ ខេត្តព្រៃវែង ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។

ក្នុងឱកាសដ៏មហោឡារិកនោះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** បានសម្ដែងនូវការអបអរសាទរ និងរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមកសាង និងសម្ពោធបណ្ណាល័យនាពេលនេះ ដើម្បីបុព្វហេតុវិស័យអប់រំដែលជាកត្តាធានានូវអនាគតរីកចម្រើន នៃប្រទេសជាតិនីមួយៗ។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានបញ្ជាក់អំពីគោលបំណងដែលនាំឱ្យមានកសាងបណ្ណាល័យ និងហេដ្ឋារចនាសម្ព័ន្ធនានា ដែលត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់នាពេលនេះ គឺដើម្បីបន្តចូលរួមការស្តារសមិទ្ធផល បន្តទំនៀមទំលាប់ប្រពៃណី ស្ដារកេរតំណែលទាំងវត្ត ទាំងសាលារៀនរបស់គ្រួសារ និងសហគមន៍បឹងក្អែកទាំងនេះឡើងវិញ។ សម្ដែងនូវទឹកចិត្តដឹងគុណដល់លោកអ្នកមានគុណទាំងអស់ ទាំងលោកឪពុក អ្នកម្ដាយ ឧបការីជនដែលបានខិតខំកសាង និងអភិវឌ្ឍភូមិបឹងក្អែក និងឧទ្ទិសមគ្គផល កុសលផលបុណ្យ ជូនដល់លោកអ្នកមានគុណទាំងអស់ ព្រមទាំងប្រពៃណីចែករំលែក ធ្វើបុណ្យ ធ្វើទាន លើកកម្ពស់ទឹកចិត្តស្រឡាញ់ ស្នេហាជាតិមាតុភូមិយើង និងចូលរួមជាមួយនឹងរាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ជាប្រមុខដឹកនាំដែលកន្លងមកបានបំពេញការងារដ៏មហិមាជូនប្រទេសជាតិចាប់តាំងពីថ្ងៃរំដោះ៧មករា១៩៧៩រហូតមកដល់ពេលនេះ ធ្វើឱ្យប្រទេសជាតិមានសន្តិភាពពេញបរិបូរណ៍ទូទាំងប្រទេស មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ មានកិត្យានុភាពខ្ពស់ក្នុងតំបន់ ក៏ដូចជាក្នុងឆាកអន្តរជាតិ ធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពរីកចម្រើន ទាំងស្មារតី ទាំងសម្ភារជាបន្តបន្ទាប់។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ បន្តគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ដើម្បីសម្ដេចមានលទ្ធភាព



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ អញ្ជើញសំណេះសំណាលក្នុងអង្គពិធី*





ទិដ្ឋភាពក្នុងពិធីសម្ពោធបណ្ណាល័យ

បន្តដឹកនាំប្រទេសជាតិឆ្ពោះទៅរកភាពរឹងមាំរីកចម្រើនជាអមតបន្តទៅទៀត។

តាងនាមឱ្យក្រុមគ្រួសារ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានប្រកាសសម្ពោធបណ្ណាល័យនោះ ទុកជាសម្បត្តិសាធារណៈចាប់ពីពេលនេះតទៅ។

សូមជម្រាបថា បណ្ណាល័យនេះ គឺជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ដែលជាកូនចៅរបស់លោកតា **ចាន់ សាមី** និងលោកយាយ **ម៉ម មឿន** ចាប់ផ្ដើមកសាងឡើងនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២ អំពីបេតុងប្រក់ក្បឿង មានបណ្ដោយ៨,២ម៉ែត្រ ទទឹង៦,៣ម៉ែត្រ បំពាក់សម្ភាររួមមាន៖ តុ ទូ កៅអី ទូដាក់សៀវភៅ សៀវភៅពុម្ព អាន សរសេរ រឿងនិទាន និងច្បាប់ផ្សេងៗសម្រាប់រក្សាទុកក្នុងបណ្ណាល័យ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដែលចំណាយអស់ថវិកាចំនួន១៨.៣៧៩,៨៥ដុល្លារអាមេរិក៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)



ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ អញ្ជើញទស្សនាក្នុងបណ្ណាល័យ





ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ អញ្ជើញកាត់ខ្សែបូក្នុងពិធីសម្ពោធបណ្ណាល័យ និងថតរូបអនុស្សាវរីយ៍

# ព្រឹទ្ធសភារៀបចំពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា




*លោកជំទាវ មាន សំអាន (កណ្ដាល) ចូលរួមអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា*

ដើម្បីចូលរួមក្នុងឱកាសអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា នារសៀលថ្ងៃព្រហស្បតិ៍ ទី២ ខែមីនា ឆ្នាំ២០២៣ ព្រឹទ្ធសភា បានរៀបចំពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ក្រោមមូលបទ ស្ត្រីរួមគ្នា រក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថលក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា នៅសាលសិក្ខាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨រដ្ឋសភា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងនិវត្តជនជានារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសរុបចំនួន៣៥៦នាក់។

ក្នុងឱកាសនោះ លោកជំទាវ **សួន ពុធថាវី** អគ្គនាយិកានៃអគ្គនាយកដ្ឋានស្រាវជ្រាវ បានឡើងធ្វើសេចក្ដីរាយការណ៍ជូនអង្គពិធីបានជ្រាបអំពី ស្ថានភាពមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងការឡើងមានចំណាប់អារម្មណ៍តំណាងនិវត្តជនជានារី ដោយលោកស្រី **លុន ស៊ីវ៉ុន**។

ក្នុងឱកាសដ៏មហោឡារិកនេះ លោកជំទាវ **ឃួន ឃុនឌី** លេខាធិការក្រុមសមាជិកាព្រឹទ្ធសភាបានមានប្រសាសន៍ថា ទិវាអន្តរជាតិនារី គឺជាព្រឹត្តិការណ៍សកលមួយដែលជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានប្រារព្ធធ្វើឡើងក្នុងគោលបំណងរំលឹកពីវីរភាព នៃការតស៊ូទាមទារសិទ្ធិ សេរីភាព និងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព សមិទ្ធផល បញ្ហាប្រឈម ការប្ដេជ្ញាចិត្ត និងវិធានការជាវិជ្ជមាននានាក្នុងការសម្រេចបាននូវសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគ្រប់ៗរូប។ ប្រធានបទសម្រាប់ឆ្នាំ២០២៣នេះ មានគោលបំណងបន្តរំលេចពីតម្លៃ នៃការចូលរួមរបស់ស្ត្រី ដែលមិនអាចកាត់ថ្លៃបានក្នុងការថែរក្សាសុខសន្តិភាព ក៏ដូចជាកំពុងចូលរួមយ៉ាងសកម្មក្នុងការពន្លឿនកិច្ចអភិវឌ្ឍលើគ្រប់វិស័យ។ ក្នុងភាពជាដៃគូ ប្រជាពលរដ្ឋកម្ពុជាទាំង



*លោកជំទាវ សួន ពុធថាវី ឡើងធ្វើសេចក្ដីរាយការណ៍*



*លោកស្រី លុន ស៊ីវ៉ុន ឡើងមានចំណាប់អារម្មណ៍តំណាងនិវត្តជនជានារី*



*លោកជំទាវ ឃួន ឃុនឌី អញ្ជើញសំណេះសំណាលក្នុងអង្គពិធី*

ស្ត្រី និងបុរស នឹងចូលរួមដោយស្មើភាព និងស្មើសិទ្ធិជាមួយនឹងប្រជាពលរដ្ឋ នៃបណ្ដាប្រទេសនានាទាំងក្នុងតំបន់ និងសកលលោក។ ជាពិសេសនៅក្នុងយុគសម័យឌីជីថល និងនៅក្នុងរបៀបវារៈស្ថានភាពសេដ្ឋកិច្ច សង្គមក្រោយពីវិបត្តិកូវីដ១៩ ក៏ដូចជាការកសាងភាពធន់រឹងមាំ និងការអភិវឌ្ឍប្រកបដោយចីរភាព។

លោកជំទាវ **ឃួន ឃុនឌី** បានបញ្ជាក់ថា រាជរដ្ឋាភិបាលបច្ចុប្បន្នបានផ្ដល់ការគាំទ្រយ៉ាងពេញទំហឹង ព្រមទាំងបានចាត់ទុកស្ត្រីជាឆ្អឹងខ្នង នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងការងារបញ្ជ្រាបយេនឌ័រ ដែលជាកិច្ចការវិស័យក្នុងការធានាបាននូវចីរភាព សុខសន្តិភាព និងពន្លឿនល្បឿន និងកិច្ចអភិវឌ្ឍជាតិ ជាពិសេសក្នុងយុគសម័យឌីជីថល និងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ទន្ទឹមគ្នានោះ លោកជំទាវបានកោតសរសើរចំពោះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានយកចិត្តទុកដាក់ដល់មន្ត្រីរាជការជានារីទាំងអស់ និងបានកំពុងបំពេញតួនាទីក្នុងការលើកកម្ពស់កសាងសមត្ថភាព ដើម្បីធ្វើឱ្យសម្រេចបានក្នុងការអភិវឌ្ឍការងារ និងជួយពង្រឹងភាពអង់អាចត្រូវធ្វើ ព្រមទាំងជួយលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។

ជំនួសមុខឱ្យក្រុមសមាជិកាព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** បានសំណូមពរដល់បងប្អូនមន្ត្រីជានារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់ សូមបន្តថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ ទៅតាមពាក្យស្លោករបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា "អរគុណសន្តិភាព" បន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុង ចេះជួយគ្នា ការពារគ្នា និងគាំទ្រគ្នាដោយប្រកាន់ខ្ជាប់នូវសីលធម៌ រស់នៅស្អាតស្អំ រក្សាប្រពៃណីល្អ និងសេចក្ដីថ្លៃថ្នូររបស់ជាតិសំដៅរួមចំណែកថែរក្សា ការពារកិត្តិយស និងតម្លៃស្ត្រី បន្តខិតខំបង្កើនសាមគ្គីភាព ចំណេះដឹងពហុជំនាញ ជាពិសេសភាសាបរទេស និងបច្ចេកវិទ្យា ឌីជីថល ដើម្បីផ្ដល់សេវាប្រកបដោយភាពឈ្លាសវៃជូនព្រឹទ្ធសភា ឆ្លើយតបបានទៅនឹងការវិវឌ្ឍ និងតម្រូវការ នៃការងារ ថែរក្សាសុខភាពដែលជាកត្តាចម្បង ព្រោះថាសុខភាពជាដើមទុនថ្លៃបំផុតសម្រាប់ជីវិត៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)





*ទិដ្ឋភាពរួមក្នុងពិធីអបអរសាទរខួបលើកទី១១២ទិវាអន្តរជាតិនារី ៨មីនា*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញជួប សំណេះសំណាលអាជ្ញាធរឃុំចំនួន៤ ក្នុងស្រុកតំបែរ



*ឯកឧត្តម អ៊ុក ប៊ុនឈឿន ជួបសំណេះសំណាល ជាមួយអាជ្ញាធរ ក្នុងស្រុកតំបែរ*

នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរ និងក្រុមប្រឹក្សាឃុំចំនួន៤ គឺៈ ឃុំសេដា ឃុំតំបែរ ឃុំគោកស្រុក និងឃុំត្រពាំងព្រីង ស្ថិតក្នុងស្រុកតំបែរ ខេត្តត្បូងឃ្មុំ ដើម្បីស្ដាប់សំណូមពរ និងគោលការណ៍ចាំបាច់របស់ក្រុមប្រឹក្សាឃុំ ដែលផ្ដោតសំខាន់លើការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងរដ្ឋបាលឃុំ ព្រមទាំងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

ពិធីនេះមានការអញ្ជើញចូលរួមពីក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសរុបចំនួន ៤២រូប។

តាមរយៈការធ្វើសេចក្ដីរាយការណ៍របស់អាជ្ញាធរ និងក្រុមប្រឹក្សាឃុំទាំង៤ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការបម្រើសេវារដ្ឋបាលសាធារណៈ ជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលទទួលបាននូវលទ្ធផលល្អប្រសើរគួរជាទីមោទនៈ។ លទ្ធផលទាំងនេះស្ដែងឱ្យឃើញថា ព្រះរាជាណាចក្រកម្ពុជាកំពុងទទួលបានសុខសន្តិភាពពេញលេញទាំងថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន។

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបាននាពេលកន្លងមក ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានជំរុញ និងលើកទឹកចិត្តឱ្យអាជ្ញាធរឃុំបន្តយកចិត្តទុកដាក់អនុវត្តតួនាទីរបស់ខ្លួននៅក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរថែមទៀត ដោយផ្ដោតលើការផ្ដល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអត្តាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍន៍ឃុំ និងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសត្រូវធ្វើយ៉ាងណាចូលរួមស្វែង-



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិទី២ ចូលរួមក្នុងពិធីសំណេះសំណាលជាមួយអាជ្ញាធរ ក្នុងស្រុកតំបែរ*





ទិដ្ឋភាពក្នុងពិធីសំណេះសំណាល

រកដំណោះស្រាយឱ្យបានទាន់ពេលវេលាពាក់ព័ន្ធទៅនឹងបញ្ហាប្រឈម សេចក្តីត្រូវការ និងសំណូមពររបស់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរៀងៗខ្លួន។

ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ សូមបន្តយកចិត្តទុកដាក់ប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាលនានា ព្រមទាំងមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ចំពោះការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ និងត្រូវអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់បន្តចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ឱ្យបានគ្រប់ៗគ្នា។

ឯកឧត្តម បានបញ្ជាក់ផងដែរថា ចំពោះបញ្ហាប្រឈម និងសំណូមពរនៅសេសសល់ដែលអាជ្ញាធរឃុំពុំអាចដោះស្រាយបាន ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នឹងលើកជាអនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ច មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ក៏ដូចជាស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគ្រប់យន្តការនានា ដើម្បីចូលរួមរកវិធីសាស្ត្រដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្នុងបរិយាកាសដ៏ប្រសើរនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ក៏បានផ្តល់ជូនដល់អាជ្ញាធរ នៃឃុំទាំង៤ ដែលបានអញ្ជើញចូលរួម ដោយក្នុងម្នាក់ៗទទួលបានឧបករណ៍តេស្តរហ័សជំងឺកូវីដ-១៩ ចំនួន១ប្រអប់តូច និងដែលលាងដៃ១ដប ចំណុះ៥០០ml។

ដោយឡែកនាព្រឹកថ្ងៃដដែលនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន២កេសធំ ស្មើនឹង៥៤ប្រអប់តូច ផ្តល់ជូនដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រុកតំបែរ ខេត្តត្បូងឃ្មុំ៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)



ឯកឧត្តម អ៊ុក ប៊ុនឈឿន ផ្តល់ឧបករណ៍តេស្តរហ័សកូវីដ-១៩ ដល់អាជ្ញាធរ នៃឃុំទាំង៤



ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ផ្តល់ឧបករណ៍តេស្តរហ័សកូវីដ-១៩ ដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រុកតំបែរ

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលជាមួយអាជ្ញាធរ ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបង



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាល ជាមួយអាជ្ញាធរ ក្នុងស្រុកភ្នំព្រឹក*

នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានរៀបចំពិធីសំណេះសំណាលដាច់ដោយឡែកពីគ្នាជាមួយនឹងអាជ្ញាធរស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបង ក្រោមអធិបតីភាពឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ការធ្វើលិខិតបទដ្ឋានគតិយុត្ត បញ្ហាកង្វល់ បញ្ហាប្រឈម តម្រូវការ និងសំណូមពរនានាជុំវិញការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដោយផ្តោតសំខាន់លើការផ្តល់សេវារដ្ឋបាល ការងារស្ថិតិប្រជាពលរដ្ឋ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពទាំង៧ចំណុច។

បន្ទាប់ពីបានស្តាប់ការធ្វើសេចក្តីរាយការណ៍របស់អាជ្ញាធរស្រុកអំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពររួចមក ឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានជំរុញ និងលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ និងប្រធានភូមិ ត្រូវបន្តអនុវត្តតួនាទីរបស់ខ្លួននៅក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរថែមទៀត ដោយផ្តោតលើការផ្តល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍន៍ឃុំ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បញ្ហាប្រឈម តម្រូវការ សំណូមពររបស់ប្រជាពលរដ្ឋ បន្តផ្សព្វផ្សាយការចាក់វ៉ាក់សាំងកូវីដ-១៩ បញ្ហាប្រឈមនានាពាក់ព័ន្ធលើដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ និងបទល្មើសផ្សេងៗ។

ឯកឧត្តម **ប៉ុល លឹម** បានសង្កត់ធ្ងន់ថា ការងារបម្រើសេវារដ្ឋបាលសាធារណៈ គឺជាការងារដ៏សំខាន់ពីព្រោះថា ការងារនេះ នឹងស្ដែងឱ្យឃើញអំពីការយកចិត្តទុកដាក់ក្នុងការអនុវត្តការងាររបស់អាជ្ញាធរមូលដ្ឋានផ្ទាល់ ដែលធ្វើឱ្យប្រជាពលរដ្ឋមានភាពជឿជាក់ និងសេចក្ដីទុកចិត្ត។ ជាង



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ថតរូបអនុស្សាវរីយ៍ ជាមួយអាជ្ញាធរ ក្នុងស្រុកភ្នំព្រឹក*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាល ជាមួយអាជ្ញាធរ ក្នុងស្រុកសំពៅលូន*

នេះទៀត ការងាររដ្ឋបាលសាធារណៈ ក៏ជាឆ្អឹងខ្នងយ៉ាងសំខាន់មិនអាចខ្វះបាន ក្នុងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ។

ឯកឧត្តម **ម៉ុល លឹម** បានផ្ដាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ សូមបន្តប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាលនានា ព្រមទាំងមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ចំពោះការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ពីព្រោះថាជំងឺកូវីដ-១៩នេះ មិនទាន់ទៅណាឆ្ងាយពីយើងនោះទេ ដរាបណាយើងមិនយកចិត្តទុកដាក់បង្ការសុខភាពខ្លួនឯង វីរុសដ៏កាចសាហាវនេះ នឹងអាចញាំញីរាងកាយយើងបានគ្រប់ពេលវេលា ព្រមទាំងចូលរួមបន្តផ្សព្វផ្សាយជំរុញការចាក់វ៉ាក់សាំងដូសជំរុញជូនដល់បងប្អូនប្រជាជនឱ្យបានគ្រប់ៗគ្នាទៅតាមការកំណត់របស់រាជរដ្ឋាភិបាលលើផែនការការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩។

ឯកឧត្តម **ម៉ុល លឹម** បានបញ្ជាក់ថា ចំពោះបញ្ហាប្រឈម និងសំណូមពរដែលអាជ្ញាធរស្រុកទាំងពីរបានលើកឡើង ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នឹងលើកជាអនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់យន្តការនានា ដើម្បីចូលរួមរកវិធីសាស្ត្រដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្នុងឱកាស នៃពិធីសំណេះសំណាលដាច់ដោយឡែកពីគ្នានេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បាននាំយកឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ជូនអាជ្ញាធរស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ដោយក្នុងមួយស្រុកៗ ទទួលបានចំនួន៦កេស ស្មើនឹង២៧ប្រអប់ ព្រមទាំងថវិកាមួយចំនួន៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



*អាជ្ញាធរស្រុកសំពៅលូន ឡើងរាយការណ៍បញ្ហាប្រឈម និងសំណូមពរ*





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

# ក្រុមសមាជិកាព្រឹទ្ធសភាប្រជុំជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សា ថ្នាក់មូលដ្ឋានលើគម្រោង PMI-WILL



*លោកជំទាវ មាន សំអាន ដឹកនាំកិច្ចប្រជុំជាមួយសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានលើគម្រោង PMI-WILL*

នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ក្រុមសមាជិកាព្រឹទ្ធសភា បានប្រជុំជាមួយនឹងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានស្ដីពី គម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន (PMI-WILL) នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

កិច្ចប្រជុំនេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន តំណាងអ្នកសម្របសម្រួលគម្រោង PMI-WILL ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សរុបចំនួន ១៣០នាក់។



*លោកជំទាវ មាន សំអាន ឡើងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំ*

ក្នុងនាមក្រុមសមាជិកាព្រឹទ្ធសភា លោកជំទាវ **មាន សំអាន** បានបញ្ជាក់ថា កិច្ចប្រជុំនេះ គឺជាឱកាសដ៏មានសារសំខាន់សម្រាប់ធ្វើការចែករំលែកបទពិសោធន៍ស្ដីពីគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន (PMI-WILL) ជូនចំពោះក្រុមសមាជិកាព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន បានជម្រាបជូនអង្គប្រជុំជ្រាបអំពី សកម្មភាពដែលបានអនុវត្តកន្លងមក ព្រមទាំងស្នើសុំអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់លោកជំទាវប្រធានគណៈកម្មការ និងឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា ដើម្បីបន្តអនុវត្តគម្រោងឱ្យទទួលបានលទ្ធផលល្អ។

ជាមួយគ្នានោះ លោកស្រី **អ៊ុំ ឆវណ្ណចន្នី** អ្នកសម្របសម្រួលគម្រោង PMI-WILL បានជម្រាបជូនអង្គប្រជុំជ្រាបអំពី សារតាររបស់គម្រោងដែលគម្រោង PMI-WILL មានការគាំទ្រអនុវត្តពីសហព័ន្ធទីក្រុង នៃប្រទេសកាណាដា (FCM) ក្នុងភាពជាដៃគូជាមួយនឹងសមាគមរដ្ឋបាលមូលដ្ឋានក្នុងប្រទេសចំនួន៥ គឺៈប្រទេសបេណាំង កម្ពុជា ហ្គាណា ស្រីលង្កា និងប្រទេសហ្សំប៊ី។ គម្រោង PMI-WILL មានរយៈពេល៦ ឆ្នាំពីឆ្នាំ២០២១ដល់ឆ្នាំ២០២៧ ធ្វើការឆ្ពោះទៅរកគោលបំណងសំខាន់ៗ ចំនួនពីរគឺៈ ១.បង្កើនសមត្ថភាពរបស់ស្ត្រីក្នុងការដឹកនាំនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។ ២. បង្កើនសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋានក្នុងការផ្ដល់សេវាដែលមានលក្ខណៈបរិយាបន្នឆ្លើយតបនឹងយេនឌ័រ។ ទន្ទឹមគ្នានោះ លោកស្រីក៏បានបង្ហាញអំពី សមិទ្ធផល និងទិសដៅការងារបន្តរបស់គម្រោងផងដែរ។

ឆ្លងតាមរយៈការពិភាក្សាគ្នាយ៉ាងផុសផុល លោកជំទាវ **មាន សំអាន** បានបញ្ជាក់ថា លទ្ធផល នៃគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីមូលដ្ឋាន ឆ្នាំ២០២១-២០២២ និងទិសដៅ ឆ្នាំ



*ឯកឧត្តម សយ កុសល ឡើងមានចំណាប់អារម្មណ៍*



*លោកស្រី អ៊ុំ ឆវណ្ណចន្ទី ឡើងធ្វើបទបង្ហាញ អំពីគម្រោង PMI-WILL*

២០២៣-២០២៧ គឺពិតជាបានចូលរួមចំណែកជាមួយនឹងការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សមត្ថភាពស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងលើកកម្ពស់គុណភាព នៃជីវភាពរស់នៅរបស់ស្ត្រីនៅមូលដ្ឋានឱ្យកាន់តែប្រសើរ ដែលជាមូលដ្ឋានគ្រឹះសំខាន់មួយក្នុងការរួមចំណែកឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

លោកជំទាវ **មាន សំអាន** បានផ្តាំផ្ញើដល់អង្គប្រជុំសូមរួមគ្នាថែរក្សាការពារសន្តិភាព សន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ផ្លាស់ប្តូរផ្នត់គំនិតចាស់គំរឹលចំពោះស្ត្រី រួមចំណែកលុបបំបាត់អំពើហិង្សាលើស្ត្រីគ្រប់ទម្រង់ លើកកម្ពស់ការកសាងផែនការ និងរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការឆ្លើយតបទៅនឹងសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ពង្រឹងពង្រីកការបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី លើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍ តាមរយៈការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ចូលរួមលើកកម្ពស់ការយល់ដឹងរបស់បុរសក្នុងសហគមន៍ឱ្យដឹងថាបុរស និងស្ត្រីមានសមត្ថភាពដូចគ្នា ពង្រឹងសមាគមរដ្ឋបាលមូលដ្ឋាន ដើម្បីធ្វើយុទ្ធនាការតស៊ូមតិ និងកម្មវិធីអភិវឌ្ឍសមត្ថភាព ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងមានតំណាងជាស្ត្រីកាន់តែច្រើននៅមូលដ្ឋាន។

លោកជំទាវ **មាន សំអាន** មានជំនឿថា គម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាននឹងសម្រេចបានជោគជ័យតាមការរំពឹងទុក ជាពិសេសការសម្រេចបាននូវសមិទ្ធផលចុងក្រោយរបស់គម្រោង ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាព នៃជីវិតរបស់ស្ត្រី និងកុមារ ដែលមកពីក្រុមដែលបាត់បង់ឱកាស និងងាយរងគ្រោះ៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)



*លោកជំទាវ មាន សំអាន ថតរូបអនុស្សាវរីយ៍*

# លោកគ្រូ អ្នកគ្រូ និងយុវជនកាយរឹទ្ធិវិទ្យាល័យបាភ្នំ ទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភា



*ឯកឧត្ដម ម៉ែន-ស៊ីផាន់ អញ្ជើញធ្វើបទបង្ហាញ*

នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស (យុវជនកាយរឹទ្ធិ) នៃវិទ្យាល័យបាភ្នំ ខេត្តព្រៃវែង ចំនួន៥០នាក់ បានអញ្ជើញមកទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

ក្នុងឱកាសនោះ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស បានអញ្ជើញស្ដាប់បទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ដោយឯកឧត្ដម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា។ បទបង្ហាញស្ដីពីការអនុវត្តការងារជាក់ស្ដែងក្នុងដំណើរការពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់របស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយលោក **ឃិន យូរ៉ាន់** អគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងបទបង្ហាញស្ដីពី រចនាសម្ព័ន តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយលោក-ស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្ដម **ម៉ែន-ស៊ីផាន់** បានជម្រាបអំពីប្រវត្តិរបស់ព្រឹទ្ធសភា តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ភាពខុសគ្នារវាងព្រឹទ្ធសភា និងរដ្ឋសភា តួនាទី និងភារកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភានៅតាមមណ្ឌលភូមិភាគនីមួយៗ។ ឯកឧត្ដមបានបញ្ជាក់ថា ការបង្កើតព្រឹទ្ធសភាឡើង គឺជាប្រវត្តិសាស្ត្រ បញ្ចប់វិបត្តិនយោ-បាយលើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ ពង្រឹងស្ថិរ-ភាពនយោបាយ និងបង្ហាញឱ្យឃើញពីការប្ដេជ្ញាចិត្តក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋដូចអរិយៈថប្រទេសនានា។

ឯកឧត្ដម **ម៉ែន-ស៊ីផាន់** បានបញ្ជាក់ថា សមាជិកព្រឹទ្ធ-





*លោកគ្រូ អ្នកគ្រូ និងយុវជនកាយរឹទ្ធិវិទ្យាល័យ ចូលរួមក្នុងពិធីធ្វើបទបង្ហាញ*



ទិដ្ឋភាពរួមក្នុងពិធីធ្វើបទបង្ហាញ

សភាមានចំនួនយ៉ាងច្រើនស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល និងមិនចំពោះ។ សមាជិកព្រឹទ្ធសភាពីររូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភាពីររូបទៀត ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានសមាសភាពដូចជា៖ ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការទាំង១០របស់ព្រឹទ្ធសភា។ ព្រឹទ្ធសភាមានមុខងារស្នូលចំនួនបី គឺ១.មុខងារនីតិកម្ម៖ គឺមុខងារក្នុងការពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ ២.មុខងារត្រួតពិនិត្យ៖ គឺជាមុខងារដែលគណៈកម្មការនានារបស់ព្រឹទ្ធសភា តាមដាន និងត្រួតពិនិត្យការផ្សព្វផ្សាយច្បាប់ ការអនុវត្តច្បាប់ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងការអនុវត្តសកម្មភាពនានារបស់បណ្ដាក្រសួងជំនាញ។ ៣.មុខងារតំណាង៖ ជាមុខងារតំណាងឱ្យផលប្រយោជន៍ នៃក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមមណ្ឌលភូមិភាគនីមួយៗ។ ក្រៅពីនេះ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួនពីរទៀត គឺមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។

បន្ទាប់ពីស្ដាប់បទបង្ហាញរួចមក លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានានៅក្នុងបរិវេណព្រឹទ្ធសភា។

(រូបភាព៖ អ៊ុក ប៉ូលីន អត្ថបទ៖ វង់ សុជាតិ)





លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទស្សនាអគារនានា ក្នុងបរិវេណព្រឹទ្ធសភា

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា



❈នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី ១៤៦ (IPU-146) កិច្ចប្រជុំបណ្ដាញសភា នៃក្រុមប្រទេសចលនាមិនចូលបក្សសម្ព័ន្ធ (NAM) និងកិច្ចប្រជុំពាក់ព័ន្ធ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈ-កម្មការទី២ព្រឹទ្ធសភាបាន៖



-អញ្ជើញជួបពិភាក្សាការងារជាមួយលោក GREG Moran ភ្នាក់ងារស៊ុយអែត ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ Sida ក្នុងគោលបំណង ដើម្បីឈ្វេងយល់ពីលទ្ធផល នៃការផ្ដល់សេវាគាំទ្រផ្នែកស្រាវជ្រាវ និងសារ-ពើពន្ធ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ដឹកនាំកិច្ចប្រជុំជាមួយនឹងការិយាល័យអមក្រុមសមា-ជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ លេខាធិការដ្ឋានអមគណៈ-កម្មការទី២ព្រឹទ្ធសភា និងបុគ្គលិកជានារីបម្រើការងារក្នុងអគារEព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ដើម្បី៖

១-បូកសរុបលទ្ធផលការងាររៀបចំវេទិការបស់ក្រុម-



សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១

២-អបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៣ និង

៣-បញ្ហាផ្សេងៗ។



-ដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាការងាររៀបចំគ្រឿង-ឥស្សរិយយស សម្រាប់បំពាក់ជូនសមាជិកព្រឹទ្ធសភា នៅចុងនីតិកាលទី៤ព្រឹទ្ធសភា នៅសាលប្រជុំពិសេសវិមានព្រឹទ្ធសភា នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម្ញ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី៥ព្រឹទ្ធ-សភា នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បី៖

១-ពិនិត្យរបាយការណ៍សកម្មភាពការងាររបស់គណៈ-កម្មការប្រចាំខែកុម្ភៈ និងបូកសរុបរបាយការណ៍លទ្ធ-ផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

២-ពិនិត្យខ្លឹមសារ បញ្ហាប្រឈម សំណូមពរ និងលើកសំណួរសម្រាប់កិច្ចប្រជុំពិភាក្សាការងារជាមួយនឹងក្រសួងព័ត៌មាន នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ នាពេលខាងមុខ

៣-បូកសរុបរបាយការណ៍ចំណូល-ចំណាយថវិការបស់គណៈកម្មការប្រចាំខែកុម្ភៈ និងបូកសរុបចំណូល-ចំណាយថវិការបស់គណៈកម្មការប្រចាំត្រីមាសទី១

៤-បញ្ហាផ្សេងៗ។



❋នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យពិភាក្សា និងត្រៀមយោបល់លើសេចក្ដីព្រាងសេចក្ដីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអនុញ្ញាតឱ្យលោកជំទាវ **នេត្រ ភូម៉ារី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាតំណាងលោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចូលជូនពរក្នុងឱកាសអបអរសាទរខួបទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ នៅសាលគណៈកម្មការទី៨ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣។



❋នារសៀលថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារ និងរបាយការណ៍ថវិការបស់គណៈកម្មការទី១០ព្រឹទ្ធសភាប្រចាំខែមីនា និងលើកទិសដៅការងារបន្ត នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❋នាថ្ងៃទី២១ ខែកុម្ភៈ និងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធ-សភាបានអនុញ្ញាតឱ្យឯកឧត្តម **អៀង អូនី** អនុរដ្ឋលេខា-ធិការក្រសួងមហាផ្ទៃ ចូលជួបសម្ភាសន៍អំពីប្រវត្តិ នៃការបង្កើត ការវិវឌ្ឍ នៃរចនាសម្ព័ន្ធ ឈ្មោះថ្នាក់ដឹកនាំ និងតួនាទីភារកិច្ចរបស់ក្រសួងមហាផ្ទៃ ឬក្រសួងសន្តិសុខជាតិពីជំនាន់មុនៗ រហូតដល់បច្ចុប្បន្ន នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា៕

## ការទទួលពាក្យបណ្ដឹង

❋នៅខែមីនា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន៣ករណី បញ្ជូនពាក្យបណ្ដឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៤ករណី (ពាក្យបណ្ដឹងសល់ពីខែកុម្ភៈចំនួន១ករណី) ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងបានចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៣ករណី (សល់ពីខែមុនចំនួន២ករណី) ឆ្លើយតបទៅម្ចាស់បណ្ដឹង (ផ្ដល់ព័ត៌មានទៅម្ចាស់បណ្ដឹង) ចំនួន៤ករណី និងទទួលឯកសារជូនជ្រាបដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបបានចំនួន៤ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨

❋ឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ចែកអង្ករចំនួន២០០គីឡូក្រាម ដល់ក្រុមប្រឹក្សាសង្កាត់បឹងទំពុនទី១ ដើម្បីទុកចែកជូនបងប្អូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកផ្នែកជីវភាពនៅក្នុងមូលដ្ឋានសង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។



-ចែកអង្ករ និងឧបត្ថម្ភថវិកាមួយចំនួនដល់មន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី២ព្រឹទ្ធសភា មន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការក្រមសីលធម៌ និងមន្ត្រីការិយាល័យអមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅគេហដ្ឋានលេខ៥ ក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារចុះពិនិត្យ និងជំរុញការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងរៀបចំផ្ទៃដីចំនួន១០០ហិកតា សម្រាប់ដាំក្រូចថ្លុង និងដូងក្រអូប នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យចម្ការឈើហូបផ្លែ និងប្រព័ន្ធប្រឡាយទឹក ទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករបណ្ដុះកូនដូងក្រអូប និងដឹកនាំក្រុមការងារបច្ចេកទេសរៀបចំផ្ទៃដីចំនួន៤០ហិកតា ដើម្បីត្រៀមដាំដូងក្រអូបចំនួន១១.០០០ដើម ព្រមទាំងជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋកំពុងនេសាទត្រី និងឧបត្ថម្ភថវិកាមួយចំនួន នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកំសាន្ត និងទស្សនាសួនសត្វនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធីសែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យចម្ការឈើហូបផ្លែ ប្រព័ន្ធប្រឡាយទឹក ទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខព្រមទាំងណែនាំសិស្ស និស្សិត អំពីបទពិសោធន៍ការងារបច្ចេកទេសកសិកម្ម នៅវិទ្យាស្ថានកសិកម្ម ម៉ុង ឫទ្ធី កែវផុស ស្ថិតក្នុងឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលរោងចក្រផលិតចំណីសត្វ រោងចក្រជ្រៀកជ័រកៅស៊ូ និងថ្នាលបណ្ដុះកូនដូងក្រអូប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកថវិកានិងអំណោយមួយចំនួនចែកជូនសិស្សានុសិស្ស នៅសាលាបឋមសិក្សាឫទ្ធី៥ ក្នុងឃុំកែវផុស ស្រុកស្ទឹងហាវ

ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣។



❈នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ នៅឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង។

❈នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីអបអរសាទរខួប៣០ឆ្នាំ នៃការបង្កើតសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាកលវិទ្យាល័យកំចាយមារ ខេត្តព្រៃវែង។



❈នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារ ព្រមទាំងឧបត្ថម្ភថវិកាផ្ទាល់មួយចំនួន ថវិកាមួយចំនួនរបស់លោកជំទាវ **សុខឡេខ បូរ៉ា** នាយិកាពិធីការសម្តេចអគ្គមហាសេនាបតីតេជោ និងក្រមាចំនួន១៧០ មុងថ្មីចំនួន៤០ និងថ្នាំពេទ្យមួយចំនួនប្រគល់ជូនឯកឧត្តម **ម៉ៅ ហាក់** ប្រធានក្រុមការងារចុះមូលដ្ឋានឃុំជ្រៃលាស់ ព្រមទាំងឧបត្ថម្ភមន្ត្រីម្នាក់ៗនូវថវិកាមួយចំនួន ក្រមា១ និងប្រេងកូឡា១ដប នៅសាលាឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល។

❈នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យសម្ពោធឆ្លងឧបដ្ឋានសាលាថ្មី និងសមិទ្ធផលនានា ក្នុងវត្តហត្ថិវនារាម ហៅវត្តក្តុល ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី៧ ថ្ងៃទី១៦ និងថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ សង្កាត់ស្នោរ ខណ្ឌកំបូល សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ និងសង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមរបស់មូលដ្ឋាន និងការរៀបចំផ្តល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនដល់ប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័ស និងថវិកាមួយចំនួន។

❈នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំអំពិលក្រៅ នៅសាលាឃុំអំពិលក្រៅ និងចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

❈នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ញ៉ែវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀន នគរបាលប៉ុស្តិ៍រដ្ឋបាល ប្រធានភូមិ ក្រុមយុវជន និងមន្ត្រីពាក់ព័ន្ធ នៅឃុំអូរសោម ស្រុកវាលវែង



ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារចលនាកម្មករ និយោជិត នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា នៅសាលប្រជុំរំដួល ក្រុងតាខ្មៅ ខេត្តកណ្ដាល នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។



-ដឹកនាំសម្របសម្រួលកិច្ចប្រជុំរវាងឯកឧត្តម **ហ៊ី ចាវី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ ជាមួយនឹងគណៈប្រតិភូ នៃសាធារណរដ្ឋកូរ៉េ ស្ដីពីការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការវិនិយោគ នៅភូមិកណ្ដាលលើ ឃុំបន្ទាយដែកស្រុកកៀនស្វាយ ខេត្តកណ្ដាល នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីអបអរសាទរខួបលើកទី១១២



ទិវានារីអន្តរជាតិ ៨មីនា ក្រោមមូលបទ "ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" ដែលមានសមាសភាពជានារីចូលរួមសរុបចំនួន១០០នាក់ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៨ ខែមីនា ឆ្នាំ ២០២៣។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីអបអរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ នៅសាលមហោស្រប ខេត្តតាកែវ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣។



❈នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធវិហារឥស្លាមម៉ាស្ជិទនូរុលមូលស៊ីនីន និងសមិទ្ធផលនានា នៅភូមិសំរោង ឃុំរមេញ ស្រុកកោះអណ្ដែត ខេត្តតាកែវ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាអគ្គមេបញ្ជាការកងទ័ពជើងគោក។

❈នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែ និងលើកទិសដៅការបន្តរបស់រដ្ឋបាលឃុំឫស្សីស្រុក នៃស្រុកពាមជរ នៅខេត្តព្រៃវែង។

❈នាព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ចាន់ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសុភមង្គល ស្ថិតក្នុងភូមិសាលាបាឡាត់ សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។



❈នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង ជូននិស្សិតជ័យលាភី សកលវិទ្យាល័យឯកទេស នៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសុភមង្គល ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី បច្ចេកទេសជំនាញ និងបទពិសោធន៍ពាក់ព័ន្ធនឹងការចរចា និងសន្ទានកម្ម ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលសភាកម្ពុជា នៅខេត្តសៀមរាប។

❈នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឆាយ ខណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី ខណ្ណថា** សមាជិកាគណៈ-



កម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតថ្នាក់បរិញ្ញាបត្រ បរិញ្ញា-បត្ររង គិលានុបដ្ឋាក ឆ្មប គិលានុបដ្ឋាកបច្ចេកទេស មន្ទីរពិសោធន៍ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ហ៊ីន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាអគ្គមេបញ្ជាការកងទ័ពជើងគោក នៅសាកលវិទ្យា-ល័យកំពង់ចាម ភូមិតាណោង សង្កាត់សំបូរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួម៖



-ក្នុងពិធីសំណេះសំណាល និងផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្តីសម្រេចចិត្តសង្ឃសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ២០២២ ជូនដល់គណៈកម្មការអាចារ្យវត្ត សីលវន្ត សីលវតី និងសិស្ស និស្សិតស្នាក់នៅវត្តស្លែង ខណ្ឌដង្កោ វត្តចំនួន២១ ខណ្ឌច្បារអំពៅ និងវត្តចំនួន១៦ ខណ្ឌព្រែក-ព្នៅ រាជធានីភ្នំពេញ នាថ្ងៃទី៣ និងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។

-ពិធីសំណេះសំណាល និងផ្តល់ឱវាទអប់រំចរិយាធម៌សីលធម៌ ស្តីពី "អត្តាហិ អត្តនោ នាថោ" ក្រោមព្រះអធិបតី-ភាពសម្តេចព្រះសាក្យមុនី កិត្តិបណ្ឌិតទស្សនវិជ្ជា **វ៉ន្ត សាឿន** ព្រះអនុគណខណ្ឌសែនសុខ ជូនដល់ជនរងគ្រោះដោយគ្រឿងញៀន នៅមជ្ឈមណ្ឌលឱកាសខ្ញុំ ខណ្ឌសែន-



សុខ រាជធានីភ្នំពេញ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣។



-ប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាជួយថៃទាំការពារសុខភាពមនុស្សចាស់ប្រចាំខែមីនា នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅភូមិគ្រោក និងភូមិព្រះពន្លា ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៥ ខែកុម្ភៈ និងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការអនុវត្តផែនការសកម្មភាពរបស់ស្រុកកំពង់រោទិ៍ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំញាយ ឃុំវល្លិសរ ឃុំខ្ពុំក្រាំង ឃុំតាំងក្រូច ឃុំកាហែង និងឃុំទំព័រមាស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោត ព្រមទាំងនាំយកអំណោយចែកជូនសមាជិក នៃអង្គពិធីក្នុងម្នាក់ៗទទួលបានក្រមា១ នំប៉ុង១ដើម និងឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១ប្រអប់ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣។




-ចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលជាមួយនឹងកងកម្លាំងប្រដាប់អាវុធទាំង៤ប្រភេទ ចំនួន២០០នាក់ ក្នុងបរិវេណសាលាខេត្តកំពង់ស្ពឺ នៅខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំក្រាំងអំពិល ឃុំធម្មតាអរ និងឃុំស្គុះ ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយចែកជូនដល់សមាជិក នៃអង្គពិធីក្នុងម្នាក់ៗទទួលបានក្រមា១ នំប៉ុង២ដើម ត្រីខ១កំប៉ុង និងឧបករណ៍តេស្តកូវីដ-១៩ ១ប្រអប់ នៅឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ឧបដ្ឋានសាលា និងសមិទ្ធផលនានា ក្នុងវត្តក្រាំងចេក ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ នៅឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំង

១៥ឃុំ របស់ស្រុកឧដុង្គ ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុងឧដុង្គម៉ែជ័យ និងស្រុកសាមគ្គីមុនីជ័យ និងការងារត្រៀមរៀបចំការបោះឆ្នោត ព្រមទាំងនាំយកអំណោយចែកជូនដល់សមាជិកនៃអង្គពិធី ក្នុងម្នាក់ៗទទួលបានក្រមា១ ឧបករណ៍តេស្តរហ័សកូវីដ-១៩ ១ប្រអប់ និងថវិកាមួយចំនួន នៅសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធី៖

-សំណេះសំណាលខួបលើកទី១១២ ទិវានារីអន្តរជាតិ ៨មីនា ក្រោមអធិបតីភាពលោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩រដ្ឋសភា នៅខេត្តតាកែវ នាថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣។

-បិទសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តតាកែវ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៅសាលប្រជុំរបស់រដ្ឋបាល សាលាខេត្តតាកែវ នាថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។

-សម្ពោធវិហារឥស្លាម និងសមិទ្ធផលមួយចំនួន ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតនាយឧត្តមសេនីយ៍ **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិសំរោង ឃុំរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។

❈លោកជំទាវ **គង់ សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខថ្នាក់ដឹកនាំរដ្ឋបាលស្រុកឈូក មន្ត្រី និងបុគ្គលិកសុខាភិបាល នៃស្រុកប្រតិបត្តិឈូក មន្ទីរពេទ្យបង្អែកចំនួនពីរ មណ្ឌលសុខភាពទាំង១៣ និងក្រុមប្រឹក្សាឃុំចំនួន១៥ឃុំ ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១៣៧ប្រអប់ ជូនដល់រដ្ឋបាលស្រុក មន្ទីរពេទ្យបង្អែកទាំង២ មណ្ឌលសុខភាពទាំង១៣



និងឧបត្ថម្ភថវិកាមួយចំនួនដល់ប្រធានឃុំទាំង១៥ឃុំ នៅសាលប្រជុំសាលាស្រុកឈូក ខេត្តកំពត នាព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល សួរសុខទុក្ខថ្នាក់ដឹកនាំរដ្ឋបាលស្រុកដងទង់ កងកម្លាំងប្រដាប់អាវុធ មន្ត្រី និងបុគ្គលិកសុខាភិបាលនៃស្រុកប្រតិបត្តិដងទង់ មណ្ឌលសុខភាពទាំង៦ និងក្រុមប្រឹក្សាឃុំចំនួន១០ឃុំ ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៩៦ប្រអប់ ជូនដល់រដ្ឋបាលស្រុក កងកម្លាំងប្រដាប់អាវុធទាំងបី ការិយាល័យស្រុកប្រតិបត្តិ មណ្ឌលសុខភាពទាំង៦ និងឧបត្ថម្ភថវិកាជូនដល់ប្រធានឃុំទាំង១០ឃុំ នៅសាលប្រជុំសាលាស្រុកដងទង់ ខេត្តកំពត នារសៀលថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ លោកតា លោកយាយ មន្ត្រីរាជការ គ្រូពេទ្យ អតីតយុទ្ធជន និងនិវត្តជន ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣។

❋ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញៈ



-ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានា ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅវត្តគីរីរុក្ខារាមថ្មរមៀល ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ នៅសាលប្រជុំធំសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។



❋នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធឧបដ្ឋានសាលា និងសមិទ្ធផលនានានៅវត្តសុវណ្ណគិរី (ហៅវត្តជៀស) ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាអគ្គមេបញ្ជាការកងទ័ពជើងគោក នៅភូមិជៀសទី២ ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញៈ

-រៀបចំពិធីបុណ្យគម្រប់ខួប២ឆ្នាំជូនដល់មហាឧបាសិកា **កែវ ហ៊ាង** និងប្រគេនចង្ហាន់ព្រះសង្ឃចំនួន៤០អង្គជាកិច្ចបង្អើយបុណ្យ នៅវត្តសន្តិភាព ស្ថិតក្នុងភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមជាមួយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យរៀបចំទីតាំងដីសម្បទានសង្គមកិច្ចមានទំហំ៣០០ហិកតា នៅជិតបណ្ដោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម ដើម្បីរៀបចំសង់លំនៅឋានចំនួន១០០ខ្នង ជូនគ្រួសារយោធិន នគរបាល និវត្តជន គ្រួសារពលី និងគ្រួសារទីទ័លក្រ នៅចន្លោះបង្គោលលេខ២០២ និង២០៣ ឃុំចន្ទ្រា ស្រុកចន្ទ្រា និងឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យខួបទិវានារីអន្តរជាតិ៨មីនា ខួបលើកទី១១២ នៅសាលាបឋមសិក្សាកន្ទុយវៃ ព្រមទាំងបាននាំយកអំណោយ រួមមានៈ ក្រណាត់ អាវ សំពត់ ស៊ីង សៀវភៅសិស្ស ប៊ិក ខ្មៅដៃ ជួយសាងសង់ឡដុតសំរាម និងបានជួយចាក់ដីសាលា នៅសង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមកម្មវិធីបុណ្យសពលោកជំទាវ **សេក សុខ** ត្រូវជាភរិយាឯកឧត្តម **យស់ សាម៉ុល** អតីតសមាជិកក្រុមប្រឹក្សាខេត្តស្វាយរៀង អាណត្តិទី២ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីផ្សព្វផ្សាយអំពី សមិទ្ធផលនានាដែលសម្រេចបាន ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ចំនួន៤ប្រអប់ ជូនឃុំ ចរិកាមួយចំនួន និងសារុងម្នាក់មួយៗ នៅភូមិព្រៃបឹង ឃុំម៉ឺនជ័យ ស្រុករំដួល ខេត្តស្វាយរៀង នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣។

❃ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្ម-ការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមក្នុងពិធីបើកវគ្គហ្វឹកហ្វឺនក្បាច់គុន នៃកងយោធ-ពលខេមរភូមិន្ទ ជូនដល់សិក្ខាកាមជានាយទាហាន នាយ-ទាហានរង និងពលទាហាន មកពីអង្គភាពចំណុះយោធភូមិភាគទី៥ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ទោ **សេខ ឆារិន** មេបញ្ជាការស្តីទីយោធភូមិភាគទី៥ ស្ថិតក្នុងទីបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ស្រុកព្រះនេត្រ-ព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមពិធីបូកសរុបលទ្ធផលការងារក្រុមប្រឹក្សា សង្កាត់ ឃុំ និងយុវជនប្រចាំឆ្នាំ២០២២ និងទិសដៅការងារបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀននាយប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ និងប្រធានភូមិ ដើម្បីផ្លាស់-ប្តូរបទពិសោធន៍គ្នា ទៅវិញទៅមកអំពី ការអនុវត្តច្បាប់ ការធ្វើលិខិតបទដ្ឋានគតិយុត្ត បញ្ហាប្រឈម សំណូមពរ ដោយផ្តោតសំខាន់លើការផ្តល់សេវារដ្ឋបាល និងការអនុវត្តគោល-នយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ និងថវិកាមួយចំនួននៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី៩ ខែមីនា ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាការពារភូមិជូនល្វាយ និងភូមិពន្លៃចាស់ នៅឃុំទ្រាស់ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ព្រមទាំងចែកអាវុធ ចំនួន៧គ្រឿង និងខោចែវ នាថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។



-ជាគណៈអធិបតីភាពក្នុងកម្មវិធីល្អមែន CARAVAN បើកបរម៉ូតូ Dream 2023 របស់ក្រុមហ៊ុនម៉ូតូហុងដា សាខាខេត្តបន្ទាយមានជ័យ នៅបរិវេណខាងជើងខ្លោងទ្វារវត្តប្រិយ៍ ឃុំរលួស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣។



-ជាគណៈអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកុដិ១ខ្នង កម្ពស់២ជាន់ ព្រមទាំងសមិទ្ធផលនានា ក្នុងវត្តពោធិ៍ឧត្តមរាមប្រាសាទពង្រតាផូ នៅឃុំតាផូ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣។

❃លោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីជួបសំណេះសំណាល និងផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣០ និងសេចក្តីសម្រេចចិត្តសង្ឃសន្និបាតមន្ត្រីសង្ឃ រាជធានីភ្នំពេញប្រចាំឆ្នាំ២០២២ ប្រគេន និងជូនដល់ព្រះសង្ឃ គណៈកម្មការអាចារ្យវត្ត សីលវ័ន្ត សីលវតី និងសិស្ស និស្សិតស្នាក់នៅទាំង២១វត្ត នារសៀលថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនាទីថ្នាក់ដឹកនាំ

នៅថ្នាក់ក្រោមជាតិ ចំនួន២៣៧នាក់ ដើម្បីអបអរសាទរខួប លើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅរាជធានីភ្នំពេញ នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសំណេះសំណាល អបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ជាមួយនឹងថ្នាក់ដឹកនាំជាស្ត្រី ភរិយា ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកកិច្ចសន្យាខណ្ឌជានារី លោកស្រីចៅសង្កាត់ ប្រធានភូមិ លោកស្រីនាយិកា នាយិការងសាលាមត្តេយ្យ លោកស្រីអធិការខណ្ឌ សរុបចំនួន៣២៧នាក់ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី៖



-សម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានា ក្នុងវត្តខេមឃោសារាម(ហៅវត្តទួលទ្រាជើង) ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ នៅឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សក្នុងឃុំជីគរ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ នៅឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣។

-សម្ពោធផ្លូវបេតុង កុដិថ្ម (៣ជាន់) និងសមិទ្ធផលនានាក្នុងវត្តមង្គលបុរី (ហៅវត្តមង់) ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ នៅភូមិមង់ទី៦ ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។



❈នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ ស្មៀន និងឈ្វេងយល់អំពីការប្រឈម និងការលំបាកក្នុងការអនុវត្តការងារក្នុងមូលដ្ឋាន ព្រមទាំងនាំយកសៀវភៅទិនានុលេខន៍ ប្រតិទិន និងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមប្រឹក្សាឃុំកណ្តោល នៅស្រុកបុទុមសាគរ ខេត្តកោះកុង។



❈នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្តម **ឌឹម លាច** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី ចណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងឈ្វេងយល់ពីសកម្មភាពក្រុមប្រឹក្សាឃុំ ស្មៀន នាយកសាលា មណ្ឌលសុខភាព ប្រធានភូមិទាំង១០ នៃឃុំត្រពាំងគរសរុបចំនួន៤៦នាក់ ព្រមទាំងនាំយកនូវអំណោយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា មានឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ចំនួនមួយកេសធំជូនមណ្ឌលសុខភាពឃុំ និង



ឧបត្ថម្ភថវិកាមួយចំនួន។

❋នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ឯកឧត្ដម **ជឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្ដម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្ដិ៍ មណ្ឌលសុខភាព ប្រធានភូមិ ចំនួន៥៥នាក់ ដើម្បីឈ្វេងយល់ពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ព្រមទាំងនាំយកអំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ជូនរដ្ឋបាលស្រុក និងការិយាល័យស្រុកប្រតិបត្តិ នៅសាលាស្រុកព្រៃឈរ ខេត្តកំពង់ចាម។

❋នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្ដម **ញ៉ូង សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយគម្រោងសំណង់វារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ចំនួន៣៤២គ្រួសារ និងការពិនិត្យវឌ្ឍនភាព នៃការសាងសង់ទំនប់វារីអគ្គិសនី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិស្រែតាំងយ៉ ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

❋ឯកឧត្ដម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីសម្ពោធព្រះវិហារ និងសមិទ្ធផលនានា នៅវត្តសមារង្សី ដោយមានការអញ្ជើញចូលរួមពីប្រជាពលរដ្ឋចំនួន៦០០នាក់ ព្រមទាំងនាំយកថវិកាមួយចំនួនរបស់ឯកឧត្ដម **ហ៊ុន ម៉ានិត** ឧបត្ថម្ភជូនប្រជាពលរដ្ឋនៅភូមិសំរោង ឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សម្ដេចឧត្ដមទេពញាណ **ហ៊ុន ណេង** ចុះពិនិត្យ ព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋចំនួន២៧៤នាក់ និងព្រះសង្ឃចំនួន១០អង្គ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៅវត្តព្រែកសង្កែ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្ដម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋគ្រូបង្រៀនខ្មែរឥស្លាម និងថ្នាក់ដឹកនាំឥស្លាម នៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់ក្រុង ឃុំកំពង់គ្រែង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣។

❋នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្ដម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាឯកឧត្ដម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ព្រមទាំងចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តសៀមរាប។

❋លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូនៅសាលាបឋមសិក្សាខ្សាច់ជីរស់ និងនាំយកអំណោយចែកដល់សិស្សានុសិស្សចំនួន២៥០នាក់ ដោយសិស្សម្នាក់ៗទទួលបាន៖ នំប៉័ងផ្អែម១ដើម ទឹកបរិសុទ្ធ១ដប កាតាបយួរ១ សៀវភៅ២ក្បាល ប៊ិក២ដើម និងថវិកាមួយចំនួន ព្រមទាំងលោកគ្រូ អ្នកគ្រូចំនួន១៧នាក់ ក្នុងម្នាក់ៗទទួលបាន៖ ក្រមា១ និងថវិកាមួយចំនួន នៅសាលាបឋមសិក្សាខ្សាច់ជីរស់ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។



-នាំយកសម្ភារៈរួមមាន៖ អង្ករ១បាវ មី២កេស ត្រីខ២យួរ ទឹកត្រី២យួរ ទឹកស៊ីអ៊ីវ២យួរ និងថវិកាមួយចំនួនចូលរួមពិធីបុណ្យសព លោក **ស្រី ណាល់** អតីតមេឃុំ ដែលបានទទួលមរណភាព នៅភូមិកំពង់គោលើ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០២៣ និងចែកវត្ថុអនុស្សាវរីយ៍ ក្នុងម្នាក់ៗទទួលបាន៖ ក្រណាត់ប៉ាក់១ដុំ ព្រមទាំងពិសានំបញ្ចុកសាមគ្គី នៅសាលាស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្ដម **អ៊ុក គន់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធ៖



-ដាក់ឱ្យប្រើប្រាស់អគារសិក្សា នៃសាលាបឋមសិក្សានិតព្រីលចំនួន១ខ្នង២ជាន់ ចំនួន១២បន្ទប់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅភូមិគរ ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង នារសៀលថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣។

-ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្មសាខាខេត្តបាត់ដំបង ក្រោមអធិបតីភាពឯកឧត្តម **វង់ សណ្តាប់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅភូមិអញ្ចាញ សង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ស្រី ថេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានស្តារ និងលើកកម្រិតគុណភាពផ្លូវជាតិលេខ៣១ និងលេខ៣៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ នាយប៉ុស្តិ៍រដ្ឋបាលឃុំសិង្ហ ក្នុងការរៀបចំផែនការឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នាំ២០២៣ និងឧបត្ថម្ភថវិកាមួយចំនួន នៅសាលាឃុំសិង្ហ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១៥ ខែមីនា ឆ្នា២០២៣។

❈ឯកឧត្ដម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-នាំយកទេយ្យវត្ថុ គ្រឿងឧបភោគ បរិភោគ និងបច្ច័យទៅប្រគេនព្រះចៅអធិការវត្តទេពពោធិ៍វង្ស (ហៅវត្តថ្មី) ដែលកំពុងអាពាធ នៅសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ចូលរួមពិធីសម្ពោធស្តូបរង្វង់មូល ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី ទទួល



បន្ទុកបេសកកម្មពិសេស ជាអនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២ ខែមីនាឆ្នាំ២០២៣។

-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក អភិបាលស្រុកត្រពាំងប្រាសាទ និងស្រុកចុងកាល់ ដើម្បីស្តាប់សភាព-ការណ៍រួមក្នុងមូលដ្ឋានខែមីនា ឆ្នាំ២០២៣ និងទិសដៅការងារបន្តខែមេសា ឆ្នាំ២០២៣ និងជំរុញការដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ជាអនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅឃុំចុងកាល់ ខេត្តឧត្តរមាន-ជ័យ នាថ្ងៃទី១៥ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងប្រជា-ពលរដ្ឋ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប និងឃុំផ្អាវ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ព្រមទាំងឧបត្ថម្ភភេសជ្ជៈ និងទឹកបរិសុទ្ធមួយចំនួន នាថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-គោរពវិញ្ញាណក្ខន្ធ និងរំលែកមរណទុក្ខក្រុមគ្រួសារសព



ឯកឧត្តម **នន់ យ៉ៅ** សមាជិកក្រុមប្រឹក្សាខេត្ត នៅភូមិត្រពាំងបី សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តកំពង់ឆ្នាំង និងក្រុមប្រឹក្សាឃុំ ស្មៀន ជំនួយការស្មៀនឃុំ ប្រធានប៉ុស្តិ៍រដ្ឋបាលឃុំ ប្រធានភូមិទាំង៥ នៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ដើម្បីស្តាប់ស្ថានភាពទូ-ទៅរបស់មូលដ្ឋាន ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័ស និងថវិកាមួយចំនួន នាថ្ងៃទី២ និងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខតាមខ្នងផ្ទះប្រជា-ពលរដ្ឋ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀល ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិនិត្យមើលសមិទ្ធផលនានាក្នុងវត្តអង្គរក្រៅ ភូមិអង្គរក្រៅ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ស្មៀន មេប៉ុស្តិ៍ ឃុំសេកុង

ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ចំនួន៧៥ប្រអប់តូច ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេច វិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ជូនដល់ក្រុមប្រឹក្សាឃុំទាំង៥ នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងអាជ្ញាធរខេត្តស្ទឹងត្រែង មណ្ឌលសុខភាពស្ទឹងត្រែង និងមណ្ឌលសុខភាពសាមគ្គី ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ចំនួន៧៤៥កេស ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ជូនដល់សង្កាត់ទាំង៤ នៅសាលាសង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំស្រុកអង្គរធំ ដើម្បីបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ និងលើកទិសដៅការងារបន្ត នៅស្រុកអង្គរធំ ខេត្តសៀមរាប។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកទេយ្យទានដែលរួមមានអង្ករ១០០គីឡូក្រាម និងបច្ច័យមួយចំនួនវេរប្រគេនព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសីយ៍ និងវត្តព្រះឥន្ទកោសា ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ដែលមានអ្នកចូលរួមចំនួន២០២នាក់ នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈ពីថ្ងៃទី៩ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជាចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៦ (IPU-146) កិច្ចប្រជុំបណ្តាញសភា នៃក្រុមប្រទេសចលនាមិនចូលបក្សសម្ព័ន្ធ (NAM) នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។



❈នាថ្ងៃទី១ ដល់ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការកិច្ចការសភា និងបណ្តាញស្ត្រី នៃសភាប្រើប្រាស់ភាសាបារាំង (APF) នៅទីក្រុងរ៉ាបាត នៃព្រះរាជាណាចក្រម៉ារ៉ុក៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❋នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្ដម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិសាអាហារការងារពេលល្ងាចជាមួយនឹងឯកឧត្ដម Mr. UENO Atsushi ឯកអគ្គរាជទូតជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា។

❋នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ឯកឧត្ដម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សៀវភៅដល់បណ្ណាល័យនៅវិទ្យាល័យតេជោ ក្រុងក្រចេះ ខេត្តក្រចេះ ក្រោមអធិបតីភាពឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

❋នាព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ សមាជិកាព្រឹទ្ធសភាចំនួន៧រូប បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅវិមានសន្តិភាព។



❋នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្ដម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្ដម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញបំភ្លឺជូនក្រុមប្រឹក្សាធម្មនុញ្ញ លើសេចក្ដីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅក្រុមប្រឹក្សាធម្មនុញ្ញ។

❋ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពី ការលើកយកបញ្ហាអាជីវកម្មលើវិស័យកសិកម្ម និងវិស័យកសិ-ឧស្សាហកម្ម និងបញ្ហាផ្សេងៗ ស្នើសុំទៅរាជរដ្ឋាភិបាលជួយដោះស្រាយ នៅសាលប្រជុំសភាពាណិជ្ជកម្មកម្ពុជា នាព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។

-ទទួលជួបភ្ញៀវជាតិចំនួន១០០នាក់ អញ្ជើញមកសិក្សាឈ្វេងយល់អំពីហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធប្រឡាយទឹកនៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងទស្សនាសួនសត្វ ព្រះវិហារ និងសហចេតិយ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣។

-ទទួលជួបអ្នកវិនិយោគជនជាតិជប៉ុនលោក EIjI Hatano អញ្ជើញមកសិក្សាឈ្វេងយល់អំពីការងារកសិកម្ម កសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២២ និងលើក



ទិសដៅឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគារផ្ការំដួល សាលសែនពិដោរ នារសៀលថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។



❈នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ម៉ែន ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **អ៊ឹង លាងហ៊្វ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកជាផ្លូវការពិធីបុណ្យទន្លេលើកទី៧ ឆ្នាំ២០២៣ ក្រោមប្រធានបទ “ទន្លេរបស់យើង ដើម្បីបច្ចុប្បន្ន និងអនាគត (Our River for Now and Next)” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅខេត្តកំពង់ធំ។

❈នាព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបើកសន្និសីទជនមានពិការភាពប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកលើកទី៥ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព។

❈នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងងពិធីទទួលវត្ថុបុរាណដែលបានប្រគល់ជូនព្រះរាជាណាចក្រកម្ពុជាវិញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ២០២៣ ខួបទី១១២ និងបូកសរុបការងារ ឆ្នាំ២០២២ និងលើកទិសដៅបន្តឆ្នាំ២០២៣ របស់សាខាសមាគមនារី និងក្រុមចលនាស្ត្រីខេត្តកំពង់ចាម នៅសាលាខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងមេការ និងអ្នកគ្រប់គ្រងនៅតាមសេវាកម្សាន្តទេសចរណ៍មនុស្សពេញវ័យ សរុប៥០៩នាក់ នៅសាលាខេត្តកំពង់ចាម នារសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

-ចូលជូនពរលោកជំទាវ **អ៊ូ សាន** ភរិយា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ **អ៊ុំ សំ** ភរិយា ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុម ភា** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរខួបលើក



ទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ នៅគេហដ្ឋានលេខ១៦ ផ្លូវលេខ២២២ ភូមិ៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងស្ត្រីជាថ្នាក់ដឹកនាំ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស និងអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា នៅរាជធានីភ្នំពេញ នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងចែកចង្ក្រានសន្សំសំចៃថាមពលជូនប្រជាពលរដ្ឋក្រុងកែប ចំនួន១.៤០៥ គ្រួសារ នៅពហុកីឡដ្ឋានខេត្តកែប ក្នុងនោះប្រជាពលរដ្ឋសង្កាត់កែប ចំនួន២ភូមិ ទទួលបាន២៦៩ចង្ក្រាន ប្រជាពលរដ្ឋសង្កាត់ព្រៃធំចំនួន៣ភូមិ ទទួលបាន៦០៥ចង្ក្រាន និងប្រជាពលរដ្ឋសង្កាត់អូរក្រសារ ចំនួន២ភូមិ ទទួលបាន៥៣១ចង្ក្រាន នារសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ នៅសាលសន្និសីទបូកគោ ខេត្តកំពត នាព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារប្រចាំឆ្នាំ២០២៣ របស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកំពត នៅសាលសន្និសីទបូកគោ ខេត្តកំពត នារសៀលថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសម្ពោធការចាក់ផ្សាយភាពយន្តប្រវត្តិសាស្ត្រកូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅមជ្ឈមណ្ឌលសន្និបាតជ្រោយចង្វារ រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣។



-ចូលរួមប្រជុំពិនិត្យពិភាក្សាលើការងារសំខាន់ៗរបស់សម្ព័ន្ធភាពសង្គមស៊ីវិល ដើម្បីសន្តិសុខមនុស្សជាតិ សាមគ្គីភាព និងអភិវឌ្ឍន៍មាតុភូមិកម្ពុជា នាព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

-ចូលជួបសម្តែងការគួរសម និងគោរពជូនពរសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង



សម្ដេចធម្មវិសុទ្ធវង្សា **សៅ ទី ហេងសំរិន** ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅភូមិគ្រឹះសម្ដេចស្ថិតក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្ដម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី ការផ្ដល់ភាពអង់អាចក្លាហានដល់យុវជន ការអប់រំការងារ សិទ្ធិមនុស្ស និងសុខភាពបន្ដពូជ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅអគារ KAMPUS រាជធានីភ្នំពេញ។



❈នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ែនស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងមន្ត្រីជានារីបម្រើការនៅលេខាធិការអមគណៈកម្មការ ក្នុងឱកាសអបអរសាទរខួបទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា។

❈នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៣ លោកជំទាវ **កង សៅរ៍ឆែន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាគណៈអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងនារីថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិចំនួន២៣៧រូប ដើម្បីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅរាជធានីភ្នំពេញ។



❈នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ឯកឧត្ដម **ឆាយ ទណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្រោមអធិបតីភាពឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

❈នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ លោកជំទាវ **ខា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្ដម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្ដម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី ការផ្ដល់ភាពអង់អាចក្លាហានដល់យុវជន ការអប់រំការងារ សិទ្ធិមនុស្ស និងសុខភាពបន្ដពូជ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅរាជធានីភ្នំពេញ៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ឆ្នាំ២០២៣




*ឯកឧត្តម អ៊ុំ សារឹទ្ធ និងឯកឧត្តម ឡោក ឆាយ*

នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភានៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែកម្ភៈនេះថា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា មានភាពមមាញឹក និងសកម្មលើគ្រប់មុខងារ ហើយទទួលបានលទ្ធផលល្អប្រសើរ។ លទ្ធផលទាំងនេះក៏ផ្ដើមចេញពីការខិតខំប្រឹងប្រែងប្រកបដោយវិជ្ជាជីវៈក្នុងការផ្ដល់សេវាគាំទ្រពីគ្រប់អង្គភាពរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាផងដែរ។ ទន្ទឹមនេះសកម្មភាពការងារលេចធ្លោ ហើយទទួលបានលទ្ធផលជាទីមោទនៈសម្រាប់ស្ថាប័ន គឺការផ្ដល់សេវាសម្រាប់បម្រើឱ្យការងារបដិសណ្ឋារកិច្ចគណៈប្រតិភូប្រធានាធិបតី នៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ហើយការរៀបចំទាំងមូលនៃដំណើរទស្សនកិច្ចនេះបានជោគជ័យ និងបានឆ្លុះបញ្ចាំងអំពីភាពជោគជ័យនៃកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នល្អប្រពៃជាមួយស្ថាប័ន ក្រសួង អាជ្ញាធររាជធានី និងខេត្តសៀមរាប ព្រមទាំងភាពស្អិតរមួត ស៊ីសង្វាក់គ្នា នៃកិច្ចសហប្រតិបត្តិការផ្ទៃក្នុង។

សម្រាប់ខែមីនាខាងមុខនេះ ឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភា បានណែនាំឱ្យគ្រប់អង្គភាពទាំងអស់ ត្រូវសិក្សារៀនសូត្រនិងប្រតិបត្តិឱ្យបានរលូន និងត្រឹមត្រូវតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗនៃជំងឺកូវីដ-១៩ ជំងឺរាតត្បាតថ្មីៗ និងគ្រោះធម្មជាតិ បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ធានាប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាព នៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង ក្រៅស្ថាប័ន និងក្នុងក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយលើមុខងារទាំង៥របស់ព្រឹទ្ធសភាប្រកបដោយភាពបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត និងទាន់ពេលវេលា។

ជាមួយគ្នានេះ មន្ត្រីរាជការទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញ ជាពិសេសវិធានការ "៣ការពារ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គឹម សិទ្ធី)



*ទិដ្ឋភាពអ្នកចូលរួមក្នុងកិច្ចប្រជុំបូកសរុបសលទ្ធផលការងារប្រចាំខែកុម្ភៈ*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❋នារសៀលថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យពិភាក្សាលើការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីអគ្គលេខាធិការរងព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទាំង៥ និងប្រធានអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❋នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងលោក Wu Guoguan ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❋នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) កិច្ចប្រជុំនៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។




❋នាល្ងាចថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអគ្គលេខាធិការសភានានា ដើម្បីពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានសភាមួយចំនួនក្នុងតំបន់ នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានបន្តចូលរួមក្នុងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) ព្រមទាំងអញ្ជើញទស្សនា និងឈ្វេងយល់អំពីប្រព័ន្ធសភា នៃព្រះរាជាណាចក្របារ៉ែន។



❈នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបិទផ្លូវការនៃកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។



❈នាព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **លឹម ប៊ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញធ្វើបទបង្ហាញស្តីពី ការចែករំលែកបទពិសោធន៍កិច្ចការសភារបស់ប្រទេសបារាំង ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (អ.ព.ស.) នៅសាលាសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **លី រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញដាក់កូរ៉ោនផ្កាគោរពវិញ្ញាណក្ខន្ធសពលោក **តែ ប៊ុនលី** អតីតមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (មន្ត្រីចូលនិវត្តន៍) នៅគេហដ្ឋានសព ផ្លូវ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃសៅរ៍ ទី៤ ខែមីនា ឆ្នាំ២០២២ ខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យទីតាំងត្រៀមលក្ខណៈរៀបចំពិធីកាត់ឫសសីមា និងសមិទ្ធផលនានា ក្នុងវត្តជីខលើ ស្ថិតនៅក្នុងភូមិជិខ ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង។



❈នារសៀលថ្ងៃសៅរ៍ ទី៤ ខែមីនា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកថវិកាចូលរួមរំលែកទុក្ខសពឧបាសិកា **ហ៊ីង សារ៉េត** ម្ដាយបង្កើតលោកស្រី **ម៉ារ ម៉ូលី** នៅគេហដ្ឋាន នៃសព ស្ថិតក្នុងភូមិកោះខ្មែរ ឃុំព្រែករកា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។



❈នារសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ លោកតា **ញាណ គឿន** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនាដែលកំពុងសម្រាកព្យាបាលជំងឺ នៅគេហដ្ឋាន ស្ថិតក្នុងភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ៕



